October-2008.qxd 10/7/2008 10:51 AM Page 1

CSC
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី២ ថ្ងៃទី០១-៣១ ខែតុលា ឆ្នាំ២០០៨ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ១៤

**មាតិកា**



មហាសន្និបាត ស៊ីកនីសអាស៊ី លើកដំបូង... ទំព័រ ៧



លើកកម្ពស់ធនធានមនុស្សដោយ បណ្តុះបណ្តាល... ទំព័រ ៨



អាជីពគំនូរកំពុង រីកចម្រើន... ទំព័រ ១៤

# ជីវិតទុរគតរបស់ជនចាស់ជរានៅជាយរាជធានីភ្នំពេញ

ទំព័រទី១០...



SIPAR
សៀវភៅ ធ្វើអោយអ្នកចេះ
មានលក់នៅតាមបណ្ណាគារ និងតូបលក់សៀវភៅនានា
023 216 001
siparedition@online.com.kh



កម្មវិធីវិទ្យុ
**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ ថ្ងៃ សៅរ៍/អាទិត្យ
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:០០-១៣:០០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 100.5 Mhz ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
កំពត : FM 92.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

October-2008.qxd 10/7/2008 10:51 AM Page 2

# សារសម្តេចប៉ាប បេណេឌីកទី១៦ សម្រាប់ ថ្ងៃអាទិត្យ ទី១៩ ខែតុលា ក្នុងទិវាបេសកកម្មពិភពលោក



**បងប្អូនជាទីស្រលាញ់ !**

នៅថ្ងៃអាទិត្យ ទី១៩ ខែតុលា ខាងមុខនេះ ជាទិវាបេសកកម្មពិភពលោក ខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់រិះគិតពិចារណាអំពីការប្រកាសដំណឹងល្អនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង។ អាណត្តិសម្រាប់អ្នកបំពេញបេសកកម្ម គឺផ្តល់អាទិភាពខ្ពស់សម្រាប់អស់ អ្នកដែលបានទទួលពិធីជ្រមុជទឹកតាមគំរូដ៏ល្អ និងឆន្ទៈរបស់គ្រីស្តទូតប៉ូល។ ខ្ញុំសូមបង្ហាញអំពីគ្រីស្តទូតប៉ូល ជាពិសេសនៅឆ្នាំនេះព្រះសហគមន៍ប្រារព្ធឆ្នាំគ្រីស្តទូតប៉ូល។ នេះជាឆ្នាំពិសេសមួយ ដែលផ្តល់ឱកាសឱ្យយើងក្លាយជាមនុស្ស ដូចជាគ្រីស្តទូតប៉ូលដ៏ល្បីល្បាញ ដែលបានទទួលការត្រាស់ហៅឱ្យទៅប្រកាសដំណឹងល្អ ប្រាប់ទៅកាន់ជាតិសាសន៍ដទៃ។

**មនុស្សជាតិត្រូវការសេរីភាព**

មនុស្សជាតិត្រូវការសេរីភាព និងការលើកលែងទោសឱ្យរួចពីបាប។ គ្រីស្តទូតប៉ូល បានមានប្រសាសន៍ថា អ្វីៗ ដែលព្រះជាម្ចាស់បានបង្កើតមក កំពុងអន្ទះសាទន្ទឹងរង់ចាំព្រះជាម្ចាស់ នឹងបង្ហាញព្រះបុត្រារបស់ព្រះអង្គ (សូមអាន រ៉ូម ៨:១៩-២២)។ ព្រះបន្ទូលទាំងនេះពិតជាត្រឹមត្រូវនៅក្នុងពិភពលោកនេះ។ ពិភពលោកទាំងមូលកំពុងឈឺចាប់ និងរង់ចាំសេរីភាព ព្រមទាំងកំពុងរង់ចាំការផ្លាស់ប្តូរឱ្យកាន់តែប្រសើរឡើង ហើយពិភពលោកនេះក៏កំពុងរង់ចាំការសង្គ្រោះផងដែរ។ អំពើហិង្សាគ្រប់រូបភាពបង្ហាញឱ្យឃើញអំពីទំនាក់ទំនងរវាងមនុស្ស និងមនុស្ស។ ហើយភាពក្រីក្រកំពុងគំរាមកំហែងលើមនុស្សជាតិរាប់លាននាក់។ នៅពេលបច្ចេកវិទ្យាកំពុងរីកចម្រើន ហើយមិនបានផ្តល់ជាប្រយោជន៍ និងសេចក្តីថ្លៃថ្នូរដល់មនុស្សជាតិ នោះសក្តានុពល និងសេចក្តីសង្ឃឹមទាំងប៉ុន្មាន នឹងជួបភាពប្រថុយប្រថាន ដូចជាយើងឃើញនូវភាពមិនសមធម៌ និងអំពើអយុត្តិធម៌។ ទោះជាយ៉ាងណា ការគំរាមកំហែងដ៏ធ្ងន់ធ្ងរមួយ ចំពោះការទំនាក់ទំនងមនុស្ស និងបរិស្ថាន នោះគឺដោយសារការប្រើប្រាស់ធនធានដោយមិនមានការត្រួតពិនិត្យឱ្យបានត្រឹមត្រូវ ដែលនាំឱ្យមានការប៉ះពាល់ដល់សុខភាព រូបរាងកាយ និងផ្លូវចិត្ត របស់មនុស្សជាតិ។

នៅក្នុងបរិបទនេះ យើងសួរខ្លួនឯងដោយក្តីបារម្ភថា តើនឹងមានអ្វីកើតឡើងចំពោះមនុស្សជាតិ សត្វទាំងឡាយ និងពិភពលោក ? តើមានសង្ឃឹមខ្លះទេចំពោះអនាគតកាល ឬក៏អនាគតមានសង្ឃឹមខ្លះទេចំពោះមនុស្សជាតិ? តើអនាគតនឹងទៅជាយ៉ាងណា?

ចំពោះយើងទាំងអស់គ្នា ដែលមានជំនឿចម្លើយនៃសំនួរនេះគឺចេញពីព្រះបន្ទូល។ ព្រះគ្រីស្តគឺជាអនាគតរបស់យើង។ ព្រះបន្ទូលរបស់ព្រះគ្រីស្ត គឺជាការផ្លាស់ប្តូរជីវិតរស់នៅ ដែលនាំឱ្យមាន សេចក្តីសង្ឃឹម និងអនាគតត្រចះត្រចង់របស់មនុស្សទៅថ្ងៃអនាគត។

គ្រីស្តទូតប៉ូលយល់ច្បាស់ថា មានតែព្រះយេស៊ូគ្រីស្តដែលអាចធ្វើឱ្យមនុស្សលោករកឃើញការលើកលែងទោសឱ្យរួចពីបាប និងសេចក្តីសង្ឃឹម។ ដូច្នេះមនុស្សគ្រប់ៗ រូបមានតួនាទីសំខាន់ក្នុងការប្រកាសព្រះបន្ទូលព្រះគ្រីស្ត ដែលសង្គ្រោះយើងទាំងអស់គ្នា។ ឆ្លងកាត់បទពិសោធន៍របស់គ្រីស្តទូតប៉ូល យើងយល់ថា បេសកកម្មគឺធ្វើយ៉ាងណាបំពេញសេចក្តីស្រលាញ់ដែលព្រះជាម្ចាស់បានស្រលាញ់យើង។ សេចក្តីស្រលាញ់របស់ព្រះគ្រីស្តនាំឱ្យយើងរួចពីបាប និងនាំយើងទៅកាន់ **បេសកកម្មព្រះសហគមន៍សម្រាប់សាសន៍ដទៃ (Mission ad gentes)**។ សេចក្តីស្រលាញ់នេះ គឺជាកម្លាំងខាងវិញ្ញាណដែលនាំឱ្យមានសុភមង្គល យុត្តិធម៌ និងការរួបរួមគ្នាកើត មានឡើង ហើយមានតែសេចក្តីស្រលាញ់នេះ ដែលនាំឱ្យមានការអាណិតអាសូរធម៌មេត្តាករុណា និងការស្វាគមន៍។ ហើយចំណាប់អារម្មណ៍លើបញ្ហារបស់មនុស្សត្រូវបានលើកយកមកពិភាក្សា។

**ប្រកាសដំណឹងល្អគ្រប់ពេលវេលា**

ការប្រកាសដំណឹងល្អគឺជាកិច្ចការកាន់តែសំខាន់ និងជាបន្ទាន់។ សព្វថ្ងៃនេះមានមនុស្សរាប់មិនអស់កំពុងរង់ចាំទទួលការប្រកាសដំណឹងល្អ គឺអស់អ្នកដែលស្រេកឃ្លានសេចក្តីសង្ឃឹម និងសេចក្តីស្រលាញ់។

បងប្អូនជាទីស្រលាញ់! សូមឱ្យទិវាបេសកកម្មពិភពលោកនេះជួយលើកទឹកចិត្តបងប្អូនគ្រប់ៗរូបឱ្យយកចិត្តទុកដាក់ក្នុងការប្រកាសដំណឹងល្អ។

សូមឱ្យការអធិដ្ឋានថ្ងៃនេះ ជួយពង្រឹងជំនឿបងប្អូនឱ្យកាន់តែរឹងមាំឡើង ព្រមទាំងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីផ្សព្វផ្សាយពន្លឺរបស់ព្រះគ្រីស្តដែលជាពន្លឺដ៏អស្ចារ្យបំផុត ហើយនិងជួយបំបាត់នូវភាពងងឹតអន្ធកាល។

ខ្ញុំជឿ និងទុកចិត្តលើព្រះជាម្ចាស់តាមរយៈបេសកកម្មផ្សេងៗ ដែលព្រះអង្គបានចាត់មកក្នុងព្រះសហគមន៍ ព្រមទាំងដំណើររបស់គ្រីស្តទូតប៉ូល ក៏ដូចជាព្រះនាងព្រហ្មចារិនីម៉ារី ដែលជាពន្លឺនៃក្តីសង្ឃឹម រួមនិងជំនឿតែមួយ។ ហេតុនេះហើយក្នុងនាមខ្ញុំជាតំណាងព្រះសហគមន៍ ក៏សូមធ្វើការអធិដ្ឋានជូនដល់បងប្អូនគ្រប់ៗគ្នា។

ធ្វើនៅវ៉ាទីកង់ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៨

**សម្តេចប៉ាប បេណេឌីកទី១៦**



## វិចារណកថា

# មនុស្សចាស់ ជាកោសិកាសង្គមមិនអាចខ្វះបាន



Photo : L. Samphors

លោកលី សុវណ្ណា ចាងហ្វាងការផ្សាយអ្នកនាំសារ

ប្រទេសកម្ពុជាមានអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងបរទេស និងទាំងរដ្ឋាភិបាល មានកម្មវិធីអាទិភាពជាច្រើន មានជាអាទិ៍កម្មវិធីអប់រំ អភិវឌ្ឍន៍ និងកម្មវិធីផ្សេងៗ ដែលសំដៅជាពិសេសសម្រាប់កុមារ និងយុវជន។ ប៉ុន្តែគេសង្កេតឃើញថា គម្រោងសម្រាប់មនុស្សចាស់ មិនទាន់ឃើញមានអង្គការ ឬស្ថាប័នណាមួយយកចិត្តទុកដាក់ឡើយនាបច្ចុប្បន្ននេះ។

ក្នុងប្រទេសកម្ពុជា មានប្រជាជន ៥% ជាមនុស្សចាស់ចាប់ពី ៦០ឆ្នាំឡើង។ ពួកគាត់ភាគច្រើនរស់នៅជាមួយសាច់ញាតិ តែខ្លះទៀតរស់នៅក្នុងភាពក្រីក្រ និងយ៉ាប់យ៉ឺនជាទីបំផុត។

អតីតសម្តេចប៉ាប ចន ប៉ូល ទី២ មានប្រសាសន៍ក្នុងលិខិតមួយឈ្មោះ Evangelium Vitae ថា: "ទោះបីនេះជាការពិត ដែលថា គ្រួសារនាបច្ចុប្បន្ន ជាអ្នកកសាងអនាគតមនុស្សជាតិក្តី តែយើងត្រូវតែទទួលស្គាល់ថា សង្គមទំនើបបានធ្វើឱ្យគ្រួសារជួបផលវិបាក និងមានតម្រូវការច្រើន។ ដើម្បីបំពេញសេចក្តីត្រូវការនេះគ្រួសារដែលជាកោសិកាសង្គម ត្រូវចេះស្រលាញ់ និងរីករាយនឹងជីវិតរវាងសមាជិកគ្រប់វ័យ ហើយគ្រួសារនីមួយៗត្រូវការជំនួយ និងការគាំទ្រជាចាំបាច់មិនអាចខ្វះបាន។

ប្រទេសកម្ពុជាមានវប្បធម៌ចំណាស់ និងមានចាស់ទុំជាអ្នកថែរក្សាប្រពៃណី បានដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គម។ មនុស្សចាស់ជានិមិត្តរូបនៃសេរីភាព ស្នេហភាព និងការគោរព។ យើង និងក្មេងៗជំនាន់ក្រោយមានសង្ឃឹម និងរីករាយជាខ្លាំងចំពោះសមិទ្ធផល ជាច្រើនក្នុងសង្គមយើង នៅពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ ដូច្នេះយើងគួរចាប់ផ្តើមគិតគូរចំពោះមនុស្សចាស់។ យើងមិនត្រូវទុកពួកគាត់ចោលទេ។

សម្តេចប៉ាបថ្លែងថា : "វត្តមានពួកគាត់នៅក្នុងគ្រួសារ... គឺជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ដើម្បីបង្កើតនូវទំនាក់ទំនងគ្នាល្អទៅវិញទៅមក រវាងមនុស្សអាយុផ្សេងៗ" ទោះបីជាយ៉ាងនេះក្តី តាមសភាពជាក់ស្តែងមនុស្សចាស់មិនមែនកម្មវត្ថុនៃការយកចិត្តទុកដាក់ខ្លាំងណាស់ណាឡើយ នាពេលបច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជា។ នេះជាប្រការគួរឱ្យសោកស្តាយ។

CSC

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្ស៊ីវ៉ាល់ដូ។

ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា។

Licence ១៨៣ ពម.ប្រក./២៥-មិថុនា-២០០៧

មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៩ ថ្មី ដែលជាចម្រៀងពណ៌នាអំពីតង្វាយដែលថ្វាយទៅព្រះជាម្ចាស់។ តម្លៃលក់ក្នុងមួយស៊ីឌី ៨ ០០០រៀល តែប៉ុណ្ណោះ។ ហេតុដូចនេះ បើប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ជាវនោះ សូមទំនាក់ទំនងលេខទូរស័ព្ទ : ០១២ ២៤៤ ៧៧៨។

## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក

**សេវាកម្មជាទីគាប់ចិត្ត !** ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និងMP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មទាំងអស់គិតក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទាក់ទងទូរស័ព្ទ : ០១២ ៣៧៧ ៤៦០។

**សារសម្រាប់មិត្តអ្នកអាន!**

បើប្រិយមិត្តចង់មានមតិយោបល់ទៅលើអត្ថបទ មានចម្ងល់ ឬចង់ជូននូវមតិរិះគន់ស្ថាបនា សូមទាក់ទងមកកាន់អាសយដ្ឋានរបស់យើងខ្ញុំ។ យើងខ្ញុំនឹងផ្តល់នូវចម្លើយដោយក្តីរីករាយ។



**សូមប្រិយមិត្តមើល និងកំសាន្តជាមួយល្បែងរូបភាព នៅទំព័រទី ១៦ រួចទើបមើលចម្លើយនេះៗ**

**សេចក្តីជូនដំណឹង !** *"ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិកដោយមិនគិតថ្លៃ"* គ្រប់អង្គការក្រុមហ៊ុន និងស្ថាប័នទាំងអស់ដែលមានបំណងចង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬដំណឹងជ្រើសរើសបុគ្គលិកក្នុងតម្លៃទាបបំផុត ហើយចំណេញបានច្រើន សូមទំនាក់ទំនងមកកាន់ការិយាល័យអ្នកនាំសារ ឬអាចទូរស័ព្ទ : ០៩២ ៧៣៧ ២៥៥។

បញ្ជាក់ : គ្រប់ដំណឹងផ្សព្វផ្សាយជ្រើសរើសបុគ្គលិកទាំងអស់ដែលគ្មាន Logo របស់អង្គការ ក្រុមហ៊ុន ឬស្ថាប័ននានា យើងខ្ញុំនឹងចុះផ្សាយដោយមិនគិតថ្លៃឡើយ។

October-2008.qxd 10/7/2008 10:51 AM Page 4

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

**ថ្ងៃអាទិត្យ ទី២៧ ក្នុងរដូវធម្មតា ឆ្នាំ "ក" (ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៨)**

*(ម៉ាថាយ ២១,៣៣-៤៣)* ជនជាតិយូដាប្រៀបធៀបប្រជាជនគេទៅនឹងចម្ការទំពាំងបាយជូរមួយ ។ គេប្រៀបព្រះជាម្ចាស់ទៅនឹងម្ចាស់ចម្ការ(អត្ថបទទីមួយ) ។ នៅក្នុងអត្ថបទដំណឹងល្អ ព្រះយេស៊ូ (បើឱ្យត្រូវជាងលោកម៉ាថាយ) រៀបរាប់អំពីប្រវត្តិសាស្ត្ររបស់ប្រជាជនយូដា ដោយយកការប្រៀបធៀបមកលាតត្រដាង ។ ព្រះជាម្ចាស់ស្រឡាញ់ប្រជាជនអ៊ីស្រាអែលយ៉ាងខ្លាំង ។ ព្រះអង្គតាមថែរក្សាគេ ដូចម្ចាស់ចម្ការថែរក្សាចម្ការរបស់ខ្លួន ។ ម្ចាស់ចម្ការចាត់គេមកប្រមូលផល ។ ពួកគេសម្លាប់អ្នកមកប្រមូលផលវិញ ។ អ្នកមកប្រមូលផល គឺជានិមិត្តរូបអំពីព្យាការីដែលមេដឹកនាំសាសនាបានបៀតបៀន ។ នៅទីបញ្ចប់លោកចាត់កូន ដែលជានិមិត្ត រូបអំពីព្រះយេស៊ូជាព្រះបុត្រា ។

ព្រះសហគមន៍ក៏ប្រៀបដូចចម្ការរបស់ព្រះជាម្ចាស់ (១ ករ ៣,៩) ។ កុំស្មានថា ព្រះជាម្ចាស់សង្គ្រោះយើងព្រោះយើងចូលព្រះសហគមន៍នោះ ។ យើងរួមរស់ជាមួយព្រះអង្គបាន លុះត្រាតែយើងប្រព្រឹត្តនូវអំពើល្អដែលគាប់ព្រះហឫទ័យព្រះអង្គ ។

**ថ្ងៃអាទិត្យ ទី២៨ ក្នុងរដូវធម្មតា ឆ្នាំ "ក" (ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៨)**

*(ម៉ាថាយ ២២,១-១៤)* ក្នុងគម្ពីរ អ្នកនិពន្ធតែងប្រៀបធៀបអំណរសប្បាយនៃស្ថានបរមសុខ ដូចជាពិធីមង្គលការដ៏សម្បូរសប្បាយមួយ ។ ព្រះយេស៊ូប្រៀបធៀបនេះ សំដៅទៅលើប្រវត្តិសាស្ត្រអ៊ីស្រាអែល គឺព្រះជាម្ចាស់ត្រាស់ហៅគេឱ្យរួមរស់ជាមួយព្រះអង្គ ឱ្យបានអំណរសប្បាយ និងក៏ស្ថិតក្រោមការគ្រប់គ្រងរបស់ព្រះអង្គ ។ ប៉ុន្តែដោយគេមិនរវីរវល់នឹងទទួលអំណរសប្បាយនេះ ព្រះអង្គសព្វព្រះហឫទ័យហៅអ្នកផ្សេងមកជំនួសដោយមិនរាប់បុណ្យបាបជានរណាឡើយ ។ ព្រះអង្គប្រទាននូវព្រះអំណោយទានរបស់ព្រះអង្គតាមព្រះហឫទ័យប្រោសប្រណីរបស់ព្រះអង្គ ។ ព្រះអង្គពុំរវីរវល់នឹងកុសលបុណ្យរបស់យើងទេ ។ ប៉ុន្តែយើងត្រូវពាក់អាវសម្រាប់រួមក្នុងពិធីមង្គលការ គឺ "ត្រូវ"បំពាក់ព្រះគ្រីស្ត" ដោយផ្ញើជីវិតលើព្រះយេស៊ូ ។ ព្រះបិតា "សង្គ្រោះ" មនុស្សដោយសារតែព្រះហឫទ័យប្រណី មិនមែនដោយមនុស្សសន្សំបុណ្យទេ ។ ប៉ុន្តែត្រូវជឿ និងផ្ញើជីវិតលើព្រះគ្រីស្ត ។

**ថ្ងៃអាទិត្យ ទី២៩ ក្នុងរដូវធម្មតា ឆ្នាំ "ក" (ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)**

*(ម៉ាថាយ ២២,១៥-២១)* ពួកផារីស៊ីដាក់អន្ទាក់ព្រះយេស៊ូដោយសួរថា តើត្រូវបង់ពន្ធថ្វាយព្រះចៅអធិរាជឬក៏អត់ ? ប្រសិនបើព្រះអង្គមានព្រះបន្ទូលថា "ត្រូវបង់" គេអាចចោទប្រកាន់ព្រះអង្គថា ជាជនក្បត់សាសនាយូដា ពីព្រោះសុខចិត្តបម្រើខ្មាំងសត្រូវរបស់សាសន៍យូដា និងគោរពព្រះចៅជាអម្ចាស់ជំនួសព្រះអម្ចាស់តែមួយព្រះអង្គគត់ ។ ប្រសិនបើព្រះអង្គឆ្លើយថា "មិនត្រូវបង់" គេនឹងចោទប្រកាន់ថា ព្រះអង្គជាជនបង្ករឿងប្រឆាំងនឹងរាជការរ៉ូម៉ាំង ។

ព្រះយេស៊ូរំឭកទាំងគេទាំងយើងថា យើងមានព្រះអម្ចាស់តែមួយអង្គគត់ គឺអ្វីៗដែលយើងធ្វើ ហើយអ្វីៗដែល យើងគិតត្រូវតែថ្វាយទៅព្រះអម្ចាស់វិញជានិច្ច ។ យើងក៏ត្រូវស្រឡាញ់ព្រះអង្គឱ្យអស់ពីចិត្តគំនិត ។ យើងរស់នៅក្នុងស្រុកដែលមានច្បាប់ទម្លាប់ ។ យើងត្រូវគោរពតាមច្បាប់រដ្ឋ ។យើងមិនគោរពរដ្ឋអំណាចទុកជាព្រះអម្ចាស់ទេ ។ យើងក៏យកចិត្តទុកដាក់ទាមទារយុត្តិធម៌ សេរីភាព និងឱ្យរដ្ឋយកចិត្តទុកដាក់នឹងអ្នកក្រីក្រ ។ល ។ គ្មានរដ្ឋណាអាចធ្វើជាព្រះអម្ចាស់របស់ខ្លួនបានឡើយ ។

**ថ្ងៃអាទិត្យ ទី៣០ ក្នុងរដូវធម្មតា ឆ្នាំ "ក" (ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៨)**

*(ម៉ាថាយ ២២,៣៤-៤០)* ក្នុងបណ្ដាវិន័យទាំងអស់ចែងក្នុងគម្ពីរធម្មវិន័យរបស់លោកម៉ូសេ ។ ព្រះយេស៊ូរំឭកយើងអំពីវិន័យដ៏សំខាន់ជាងគេ គឺត្រូវស្រឡាញ់ព្រះអម្ចាស់ដោយស្រឡាញ់អ្នកដទៃ ។ ត្រូវស្រឡាញ់ព្រះជាម្ចាស់ឱ្យ "អស់ពីចិត្តគំនិត" មានន័យថា ត្រូវសម្រេចធ្វើអ្វីៗទាំងអស់ដោយនឹកគិតទៅដល់ព្រះអង្គជានិច្ច ។ ស្រឡាញ់ឱ្យ "អស់ពីស្មារតី" មានន័យថា គឺនឹកគិតដល់ព្រះអង្គដោយឥតឈប់ឈរ និងស្រឡាញ់ "អស់ពីប្រាជ្ញា" មានន័យថា រកគ្រប់មធ្យោបាយសម្ដែងសេចក្ដីស្រឡាញ់នោះ ។

"ត្រូវស្រឡាញ់អ្នកដទៃដូចស្រឡាញ់ខ្លួនឯង" មិនមែនជារបៀបអាត្មានិយមទេ គឺត្រូវនឹកដល់កិត្តិយស-របស់គេ និងកិត្តិយសរបស់ខ្លួនជាបុត្រធីតារបស់ព្រះបិតា ។ បើយើងគោរពតម្លៃនៃជីវិតរបស់ខ្លួន យើងក៏មិនធ្វើអំពើថោកទាបទេ ។ បើយើងគោរពអ្នកដទៃទុកជាបុត្រធីតារបស់ព្រះបិតា យើងមិនប្រព្រឹត្តអំពើអាក្រក់ណាមួយដល់គេទេ ។ តែចង់ឱ្យគេរីកចម្រើនវិញ ។

*(អ្នកនាំសារ ខែតុលា ២០០៨ - អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ / លោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងស្វដ៍)*

## យើងអាន



Photo: DR

**ប្រវត្តិសន្តប៉ូល**

ស្ដួស្ដីប្អូនៗ អ្នកនាំសារលេខនេះ សូមនាំប្អូនៗឱ្យរិះគិតបន្តពីជីវិតរបស់គ្រីស្តទូតប៉ូល។

កាលពីលេខមុន យើងបានដឹងរួចមកហើយថា គ្រីស្តទូតប៉ូល មានឈ្មោះដើមថាសូល ហើយព្រះអម្ចាស់យេស៊ូត្រាស់ហៅគាត់ ពេលកំពុងធ្វើដំណើរទៅក្រុងដាម៉ាសដើម្បីកំចាត់គ្រីស្តបរិស័ទនៅទីនោះ។ ពេលដល់ពាក់កណ្ដាលផ្លូវ ជិតដល់ក្រុងដាម៉ាស លោកត្រូវធ្លាក់ពីលើខ្នងសេះដោយសារពន្លឺដ៏ត្រចះត្រចង់ ធ្វើឱ្យភ្នែកលោកមើលមិនឃើញឡើយ។ ក្នុងរយៈពេលបីថ្ងៃ លោកមិនអ្វីមិនឃើញឡើយ។ ព្រះអម្ចាស់បានចាត់លោកអាណានីយ៉ាជាសាវ័កទៅព្យាបាលលោកប៉ូលឱ្យមើលឃើញវិញ។ ហើយលោកប៉ូលចាប់កែប្រែចិត្តគំនិតជឿលើព្រះយេស៊ូ។

**តើបន្តទៅមុខទៀតការរស់នៅរបស់គ្រីស្តទូតប៉ូលជួបប្រទះនឹងឧបសគ្គយ៉ាងណាខ្លះ ?**

ក្រោយពេលលោកជួបហេតុការដ៏អស្ចារ្យនេះ ហើយលោកបានរៀបរាប់រឿងទាំងនេះប្រាប់មនុស្សទាំងអស់។ លោកទទួលអគ្គសញ្ញាជ្រមុជទឹកជាមួយលោកអាណានីយ៉ា។ ចាប់ពីពេលនោះមក លោកក្លាយជាគ្រីស្តបរិស័ទមួយរូបដែរ។ ប៉ុន្តែមានមនុស្សខ្លះមិនពេញចិត្តទេ។ ប្អូនៗដឹងទេនៅសម័យនោះមិនខុសគ្នានឹងសម័យនេះដែរ ប្រជាជនមិនងាយចង់ក្លាយជាសាវ័ករបស់ព្រះយេស៊ូនោះទេ។

លោកប៉ូលត្រូវគេដេញតាមចាប់យកទៅសម្លាប់។ លោកបានរត់គេចខ្លួនរបស់ហូតដល់ស្រុកអារ៉ាប៊ី។ លោកត្រលប់មកក្រុងដាម៉ាសវិញ នៅបីឆ្នាំក្រោយមក។ នៅក្រុងដាម៉ាស ពួកទាហានតាមចាប់លោកទៀត។ គេបិទច្រកចេញចូលទីក្រុងទាំងអស់ និងឆែកឆេរគ្រប់ទីកន្លែង។

**តើលោកប៉ូលធ្វើដូចម្ដេចដើម្បីគេចខ្លួនបាន ?**

នៅពេលយប់ សាវ័កឯទៀតៗ បានជួយលោកប៉ូលឱ្យចាកចេញពីទីក្រុងដោយសម្រូតលោកប៉ូលតាមជាលពីលើកំផែងក្រុង។ ចាប់ពីពេលនោះ លោកបានរួចខ្លួន។ លោកប៉ូលបានគិតថា ការប្រកាសដំណឹងល្អអំពី ព្រះយេស៊ូមានការលំបាកណាស់។ ប៉ុន្តែលោកប៉ូលមិនរុញរាឡើយ។

លី សុវណ្ណា



# ព្រឹត្តិការណ៍ប្រចាំខែ

### ប្រេងឥន្ធនៈកម្ពុជាត្រូវបញ្ចុះថ្លៃតាមទីផ្សារអន្តរជាតិ

សម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានបញ្ជាឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាត់ការដើម្បីបញ្ចុះតម្លៃប្រេងឥន្ធនៈជាបន្ទាន់ នៅពេលដែលតម្លៃប្រេងលើទីផ្សារអន្តរជាតិ បានធ្លាក់ចុះដល់ទៅ២៥% ប៉ុន្តែសម្រាប់នៅប្រទេសកម្ពុជា អត្រាធ្លាក់ចុះមានត្រឹមតែ ១០% ប៉ុណ្ណោះ ។ សម្ដេចនាយករដ្ឋមន្ត្រី បានបញ្ជាក់ប្រាប់ក្រុមអ្នកសារព័ត៌មាន កាលពីថ្ងៃច័ន្ទ ទី១៥ កញ្ញា នៅទីស្ដីការគណៈរដ្ឋមន្ត្រីបណ្ដោះអាសន្ន ដែលមានទីតាំងនៅក្រសួងការបរទេសថា តម្លៃប្រេងនៅតាមស្ថានីយចាក់ប្រេងនានា នៅតែមានតម្លៃខ្ពស់ពោលគឺវាមិនទាន់ធ្លាក់ចុះស្របគ្នាតាមទីផ្សារអន្តរជាតិឡើយ ។ តាមរយៈនេះ ប្រមុខរដ្ឋាភិបាលអំពាវនាវទៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុ ឱ្យបន្តធ្វើការចាត់វិធានការដើម្បីទម្លាក់តម្លៃប្រេងលើទីផ្សារកម្ពុជាជាបន្តទៀត ។ សម្ដេច ហ៊ុន សែន បានបញ្ជាក់ថា: "វាគួរតែធ្លាក់ចុះជាងនេះ យើងខិតខំធ្វើយ៉ាងណាឱ្យមានការបញ្ចុះតម្លៃថែមទៀត" ។

### ជំរឿនដីធ្លីកសិកម្មលើកដំបូងនឹងធ្វើនៅប្រទេសកម្ពុជា

ដោយមានកិច្ចសហប្រតិបត្តិការខាងបច្ចេកទេសពីសំណាក់អង្គការស្បៀងនិងកសិកម្ម (FAO) ក្រសួងកសិកម្មនិងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនឹងរៀបចំធ្វើជំរឿនកសិកម្មលើកដំបូងនៅកម្ពុជានៅឆ្នាំក្រោយនេះ ។ គម្រោងនេះនឹងត្រូវចំណាយទឹកប្រាក់ ៤,២៨លាន ដុល្លារ ដែលនៅក្នុងនេះ អង្គការ FAO នឹងជួយជាទឹកប្រាក់ ៣៩៩.000 $ សម្រាប់ជួយរៀបចំបច្ចេកទេសជំរឿន ។ ចំណែកខាងរដ្ឋាភិបាល មានទឹកប្រាក់ ៦៨៩.៦៩០ $ ដែលស្មើនឹង ១៦,១% នៃថវិកាគម្រោង ។ ហើយបច្ចុប្បន្ន គេនៅខ្វះទឹកប្រាក់ចំនួន ៣,២លានដុល្លារទៀត ។ គម្រោងជំរឿនកសិកម្មនេះ មានរយៈពេល ២០ខែ ។ បើតាមឯកឧត្ដមឆាយ ថន រដ្ឋមន្ត្រីក្រសួងផែនការ បានបញ្ជាក់ថា លទ្ធផលនៃជំរឿនកសិកម្មនឹងក្លាយជាគោលនយោបាយដ៏សំខាន់សម្រាប់បម្រើ ឱ្យគោលដៅអភិវឌ្ឍសហវត្សរ៍នៅប្រទេសកម្ពុជា ។ ហើយជំរឿននេះក៏ជាផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ និងកម្មវិធីកំណែទម្រង់ជាច្រើនទៀត ជាពិសេសដើម្បីធ្វើឱ្យប្រសើរឡើងនៅក្នុងប្រព័ន្ធស្ថិតិកសិកម្ម និងវិទ្យា-ស្ថានជាតិស្ថិតិនៃកម្ពុជា ។

### សិស្សានុសិស្សខ្មែរឥស្លាមអាចប្រើសម្លៀកបំពាក់បែបឥស្លាមក្នុងគ្រឹះស្ថានសិក្សានានា

រដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យសិស្សានុសិស្សដែលជាខ្មែរឥស្លាមអាចប្រើប្រាស់ សម្លៀកបំពាក់តាមប្រពៃណីរបស់ខ្លួន ក្នុងគ្រឹះស្ថានសិក្សាទាំងឯកជន និងសាធារណៈ ។ នៅក្នុងសារាចរណ៍ មួយដែលចេញផ្សាយនាខែកញ្ញា ដែលចុះហត្ថលេខាដោយសម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានបញ្ជាក់ថា នេះជាការគោរពសិទ្ធិមនុស្សដែលមានចែងរួចមកហើយក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងក៏ដូចជានៅអង្គការសហប្រជាជាតិ ។ ដូច្នេះគ្រឹះស្ថានសិក្សាទាំងរដ្ឋ និងឯកជនត្រូវផ្ដល់សិទ្ធ និងសេរីភាពដល់សិស្សានុសិស្សខ្មែរឥស្លាមគ្រប់រូបដែលកំពុងសិក្សានៅក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួនក្នុងការជ្រើសរើសសម្លៀកបំពាក់មកសិក្សា ឬចូលរួមក្នុងពិធីផ្សេងៗ ទៅតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សាក៏បាន ឬតាមប្រពៃណីខ្មែរឥស្លាមក៏បាន ។

**រស់ ឌីណា**

### រថភ្លើងបុកគ្នានៅអាម៉េរិក សម្លាប់មនុស្ស ២៦នាក់



Photo: DR

ឧប្បត្តិហេតុរថភ្លើងបុកគ្នាមួយ បានកើតមានឡើង ក្នុងរដ្ឋកាលីហ្វ័រនីញ៉ា សហរដ្ឋអាម៉េរិក ហើយបានសម្លាប់ជីវិតមនុស្សអស់ចំនួន ២៦នាក់ នៅក្នុងនោះក៏មានពលរដ្ឋអាម៉េរិក ដើមកំណើតខ្មែរមួយរូបផងដែរ ។

បណ្ដាញព័ត៌មាន ប្លូមប៊ើក ក៏បានឱ្យដឹងថា ឧប្បត្តិហេតុនេះ ក្រៅពីបានសម្លាប់ជីវិតមនុស្ស ក៏ធ្វើឱ្យខូចខាត មានទឹកប្រាក់រហូតដល់ទៅ ២០០ លានដុល្លារ ។ ឧប្បត្តិហេតុនេះបានកើតមានឡើងកាលពីថ្ងៃទី១២ ខែកញ្ញាដោយការបុករវាងរថភ្លើងមេត្រូលីង និងរថភ្លើងដឹកទំនិញឈ្មោះយូញៀនប៉ាស៊ីហ្វិក មកពីទីក្រុងឡូសអានជឺឡេស ។

យោងទៅតាមកាសែតប្រព័ន្ធអ៊ីនធើណែត ឡាថែម (La Time) បានឱ្យដឹងថា ជនរងគ្រោះដើមកំណើតខ្មែរនោះឈ្មោះ យី ចាវ អាយុ ៧២ ឆ្នាំ ក៏ជាជនរងគ្រោះម្នាក់នៅក្នុងចំណោមជនរងគ្រោះខាងលើនេះ ផងដែរ ។ លោកតាយី ចាវ បានចាកចេញពីប្រទេសកម្ពុជាទៅកាន់សហរដ្ឋអាម៉េរិកតាំងពីឆ្នាំ១៩៨២ ។ សព្វថ្ងៃគាត់រស់នៅក្នុងបន្ទុកគ្រួសារ ដែលមានកូនប្រុសរបស់លោកឈ្មោះ គង់ ចាវ ។

### ថៃសម្រេចបញ្ចប់អាណត្តិនាយករដ្ឋមន្ត្រីមុនកាលកំណត់

លោកសាម៉ាក់ សុនដាវ៉ារេ នាយករដ្ឋមន្ត្រីថៃ ដែលកើតពីការបោះឆ្នោត ក្រោយពីរបបយោធាបានធ្វើរដ្ឋប្រហារទម្លាក់លោកថាក់ស៊ីន ស៊ីណាវ៉ាត្រា រួចនោះ ត្រូវតុលាការធម្មនុញ្ញប្រទេសថៃសម្រេចបញ្ចប់អាណត្តិរបស់លោកមុនកាលកំណត់ ។

ទីភ្នាក់ងារព័ត៌មានអេភី ក៏បានឱ្យដឹងថា លោកបានត្រូវតុលាការធម្មនុញ្ញ សម្រេចឱ្យលោកលាឈប់នាក្រោយពេលតុលាការនេះបានរកឃើញកំហុសមួយពាក់ព័ន្ធក្នុងកម្មវិធីចំអិនម្ហូប ឯស្ថានីយទូរទស្សន៍មួយនៅក្នុងស្រុកដែលលោកបានចូលរួម ។

ប្រភពដដែលនោះបានឱ្យដឹងថា ទោះបីជាតុលាការសម្រេច ឱ្យលោកលាឈប់ក៏ពិតមែន ប៉ុន្តែលោកបានប៉ុនប៉ងត្រឡប់មករកអំណាចវិញ ប៉ុន្តែត្រូវបរាជ័យ ។ សមាជិកគណបក្សរបស់លោកភាគច្រើនគាំទ្រលោកសំឆៃ វង់សាវ៉ាត់ ជាអនុប្រធានគណបក្សកម្លាំងប្រជាជនឱ្យជំនួសតំណែងលោក ។

លោកសំឆៃវង់សាវ៉ាត់ អាយុ៦១ឆ្នាំ ជាប្អូនថ្លៃរបស់លោកអតីតនាយករដ្ឋមន្ត្រីថាក់ស៊ីន ស៊ីណាវ៉ាត្រា ។ លោកជាអតីតមន្ត្រីនៅក្នុងក្រសួងយុត្តិធម៌ថៃនិងជាចៅក្រមនៅសាលាឧទ្ធរណ៍ ក្រោយមកជារដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងក្រសួងការងារ ។

**ខាន់ ភិរម្យ**

October-2008.qxd 10/7/2008 10:51 AM Page 6



# យើងមានអំណរសប្បាយ និងសេចក្តីស្រឡាញ់

**ឡុង សម្ផស្ស**

រៀងរាល់ឆ្នាំ ក្នុងឱកាសបុណ្យភ្ជុំប្រពៃណីជាតិ ព្រះវិហារសន្តយ៉ូសែប តែងចែកអំណោយ ជូនទៅដល់គ្រួសារក្រីក្រ។ កាលពីថ្ងៃទី១៩ ខែកញ្ញា កន្លងទៅនេះ ព្រះវិហារសន្តយ៉ូសែប បានចែកអំណោយជូនគ្រួសារក្រីក្រ ១០៥គ្រួសារ ដោយមានការចូលរួមពីសំណាក់លោកបប់ ពិសេ ជាបូជាចារ្យទទួលខុសត្រូវព្រះវិហារសន្តយ៉ូសែប ក្រុមប្រឹក្សាសង្កាត់ទួលសង្កែ តំណាងម្ចាស់អំណោយ ព្រមទាំង សមាជិកគណៈកម្មការព្រះសហគមន៍យ៉ាងច្រើនកុះករ ។

ថ្លែងនាឱកាសនោះ លោកបប់ ពិសេ មានប្រសាសន៍ថា: "នាឱកាសបុណ្យភ្ជុំឆ្នាំនេះ ព្រះសហគមន៍បានអញ្ជើញបងប្អូនមកទីនេះ ដើម្បីចូលរួមអំណរសប្បាយជាមួយគ្នា តាមរយៈការទទួលអំណោយ និងពិសាអាហារ រួមជាមួយគ្នា។ ទោះបីអំណោយទាំងនេះតិចតួចក្តី ប៉ុន្តែវាបានបង្ហាញនូវទឹកចិត្តនៃការចែករំលែកក្តីស្រឡាញ់ចំពោះបងប្អូន"។

អ្នកស្រីហួត ស៊ីមន ជាតំណាងម្ចាស់អំណោយមួយរូបមានចំណាប់អារម្មណ៍ថា: "អ្នកស្រីមានទឹកចិត្តរំភើប និងសប្បាយរីករាយជាខ្លាំង ដែលបានបរិច្ចាគអំណោយតិចតួចនាពេលនេះ។ អ្នកស្រីក៏រំពឹងថា នឹងមានឱកាសចូលរួមជួយបងប្អូនក្រីក្រ រួមជាមួយព្រះសហគមន៍នាពេលក្រោយៗទៀត ។



លោកបូជាចារ្យបប់ ពិសេ ទទួលខុសត្រូវព្រះវិហារសន្តយ៉ូសែប និងតំណាងម្ចាស់អំណោយ ប្រគល់អំណោយជូនចំពោះបងប្អូនគ្រួសារក្រីក្រ

## "តើទួលបង្គំជាអ្នកឃ្វាលប្អូនរបស់ទួលបង្គំឬ?"

ឃ្លាអត្ថបទខាងលើនេះ ត្រូវដកស្រង់ពីគម្ពីរកំណើត ៤,៩ ហើយត្រូវបានយកមកបង្ហាញនៅក្នុងសិក្ខាសាលាស្តីអំពីផលប៉ះពាល់ពីការពន្លូតកូន ដែលសិក្ខាសាលានេះរៀបចំ ឡើងដោយគណៈកម្មការសកម្មភាពដើម្បីសុខភាព ដែលប្រារព្ធធ្វើនៅព្រះវិហារសន្តយ៉ូសែប រាជធានី ភ្នំពេញ កាលពីថ្ងៃទី១៨-២០ ខែកញ្ញា ឆ្នាំ២០០៨ កន្លងទៅនេះ ដែលមានអ្នកចូលរួមប្រមាណជាង ១០០នាក់។

វាគ្មិនក្នុងសិក្ខាសាលានោះ ដែលមានលោកបូជាចារ្យ ប្រ៊ុយណូ កូសម៏ នាយកទេវវិទ្យាល័យមានប្រសាសន៍ថា ការពន្លូតកូនគឺជាការបំផ្លាញជីវិតមនុស្សទាំងស្រុង ហើយតាមរយៈនេះ ព្រះសហគមន៍សូមប្រឆាំងដាច់ខាតចំពោះបញ្ហានៃការពន្លូតកូននេះ។ នៅក្នុងព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់នូវការគោរពតម្លៃ នៃជីវិតដែលព្រះជាម្ចាស់បានប្រទានឱ្យ។

ចំណែកបងស្រីម៉ៅ ឡា ប្រធានគណៈកម្មការសកម្មភាពដើម្បីសុខភាព សម្រាប់ភូមិភាគភ្នំពេញ គូសបញ្ជាក់ថា: "គោលបំណងសិក្ខាសាលានេះ គឺជួយលើកទឹកចិត្ត និងផ្តល់ឱកាសដល់សមាជិកគណៈកម្មការសង្គហៈបានចូលរួមចែករំលែកបទពិសោធន៍ និងចំណេះដឹងទាំងក្នុងព្រះសហគមន៍ និងក្នុងសង្គមឱ្យគ្នាទៅវិញទៅមក។ ចុងក្រោយបងស្រីផ្តាំផ្ញើថា: "សូមឱ្យសមាជិកដែលបានចូលរួមយកចំណេះដឹងទៅជួយដល់អ្នកដទៃផង"។

ឡុង សម្ផស្ស

## ត.ជ.ប : ដាក់ពិនិត្យបញ្ជីឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

ក្នុងសន្និសីទសារព័ត៌មានមួយកាលពីព្រឹកថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨កន្លងទៅនេះ លោក អ៊ឹម សួស្តី ប្រធានគ.ជ.ប មានប្រសាសន៍ថា: "ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ២០០៨នេះ និងចាប់ផ្តើមពីថ្ងៃទី០១ ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨"។

នេះជាករណីយកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូប ដែលត្រូវទៅពិនិត្យនូវ បញ្ជីឈ្មោះ និងទៅចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។

កិច្ចការនេះនឹងផ្តល់ឱកាសឱ្យប្រជាពលរដ្ឋគ្រប់រូប ដែលបានចុះបញ្ជីរួចហើយនោះ គឺអាចទៅត្រួតពិនិត្យ និងសុំកែតម្រូវ ក្នុងករណីមានការខុសឆ្គង ដោយប្រការណាមួយ។ សម្រាប់អ្នកផ្លាស់ប្តូរទីលំនៅ ព្រមទាំងអ្នកគ្រប់អាយុ បោះឆ្នោត គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨នោះ ក៏អាចចុះឈ្មោះបោះឆ្នោតបាន។

ឡុង សម្ផស្ស



## ការជួយអប់រំបំប៉នជំនឿកុមារកាតូលិក គឺសំខាន់



Photo : L. Sovanna

កុមារាកុមារីប្រមាណ ១៣០នាក់ ពីព្រះសហគមន៍កាតូលិកនានា ប្រមូលផ្តុំគ្នាក្នុងអង្គសន្និបាតកុមារ សម្រាប់ព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ នៅសាលាដុនបូស្កូទឹកថ្លា ពីថ្ងៃទី៩ ដល់ទី១០ ខែកញ្ញា។ កម្មវិធីនេះដឹកនាំដោយនិស្សិតទេវវិទ្យាល័យកម្ពុជា និងយុវជនជាច្រើនរូបទៀត។

លោកបូជាចារ្យ ប្រ៊ុយណូ នាយកទេវវិទ្យាល័យកម្ពុជាមានប្រសាសន៍ថា នេះគឺជាកម្មវិធីដំបូងដែលទេវវិទ្យាល័យសាកល្បងបង្កើតឡើងសម្រាប់កុមារ និងក្មេងជំទង់។ ជាធម្មតាព្រះសហគមន៍មានកម្មវិធីជាច្រើនសម្រាប់យុវជន រិះគិតពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដូច្នេះយើងរិះគិតគួរធ្វើអ្វីមួយ សម្រាប់កុមាររិះគិតអំពីព្រះបន្ទូលព្រះជាម្ចាស់ដែរ។ ក្មេងចាប់អារម្មណ៍ច្រើនក្នុងការរិះគិតពិចារណា។ កម្មវិធីនេះជួយឱ្យកុមារាកុមារី យល់ពីវត្តមានរបស់ព្រះយេស៊ូគង់នៅជាមួយគេគ្រប់ពេលវេលា។

វណ្ណា





# មហាសន្និបាតស៊ីកនីសអាស៊ី លើកដំបូងនៅកម្ពុជា

**លី សុវណ្ណា**

ការិយាល័យផ្សព្វផ្សាយព័ត៌មាន នៃព្រះសហគមន៍កាតូលិក CSC បានរៀបចំមហាសន្និបាត ស៊ីកនីសអាស៊ី នៅឆ្នាំ២០០៨ (SIGNIS Asia Assembly 2008) ក្រោមប្រធានបទ "កុមារនៅអាស៊ី និងប្រព័ន្ធផ្សព្វផ្សាយ" ពីថ្ងៃទី១៦ ដល់១៨ ខែ កញ្ញា ឆ្នាំ២០០៨ កន្លងទៅ។ មហាសន្និបាតនេះត្រូវបានរៀបចំ នៅការិយាល័យកាសែត អ្នកនាំសារ ដែលមានអាសយដ្ឋានផ្ទះលេខ២៥ ផ្លូវ២៤២ សង្កាត់បឹងព្រលិត នៅរាជធានីភ្នំពេញ។

អ្នកចូលរួមទាំងអស់មានចំនួន ៥៤នាក់ មកពី ១៥ ប្រទេសនឹងពិភាក្សាគ្នានៅលើប្រធានបទជាច្រើនស្តីពីកុមារនៅអាស៊ី និងប្រព័ន្ធផ្សព្វផ្សាយ នៅក្នុងគោលបំណងឱ្យពិភពលោកក្រឡេកមើលកុមាររងគ្រោះទាំងឡាយ នៅក្នុងទ្វីបអាស៊ី ដើម្បីស្វែងរកមធ្យោបាយ ឱ្យប្រព័ន្ធផ្សព្វផ្សាយជួយដល់ពួកគេ។ ក្រៅពីនោះ គេពិភាក្សាអំពីការអភិវឌ្ឍន៍ថ្មីៗ របស់វិហារកាតូលិកនៅក្នុងស្រុកតាមប្រទេស និងបរិបទទាក់ទងផ្សេងៗ នៅក្នុងសង្គមកម្ពុជាផង ដែរ។

លោកបូជាចារ្យ អូមែរ ហ្ស៊ីរ៉ាល់ដូ ជានាយក CSC មានប្រសាសន៍ថា: "កម្ពុជាគឺជាប្រទេសម្ចាស់ផ្ទះនៃមហាសន្និបាតស៊ីកនីសអាស៊ី ប្រចាំឆ្នាំនេះ គឺជាកិត្តិយសមួយដែលផ្តល់ឱ្យប្រទេសកម្ពុជា ហើយក៏ជាមធ្យោបាយមួយដើម្បីលើកទឹកចិត្តគម្រោងការផ្សព្វផ្សាយនានានៅក្នុងប្រទេស មិនមែនគ្រាន់តែនៅវិហារកាតូលិកទេ គឺនៅខាងក្រៅផ្សេងៗទៀត ដើម្បីជួយដល់កុមារទាំងនោះ"។

លោកឡូរ៉េន ចន ប្រធានស៊ីកនីសអាស៊ី បានមានប្រសាសន៍ថា: "ដោយសារតែយើងទាំងអស់គ្នាដឹងថា ជនដែលងាយរងគ្រោះនៅក្នុងយុគសម័យព័ត៌មានវិទ្យានេះគឺជាកុមារ។ យើងគួរបង្កើនការយល់ដឹងចំពោះកុមារ និងព្រមទាំងមនុស្សពេញវ័យទាំងឡាយ ឆ្ពោះទៅរកទិដ្ឋភាពទាំងអវិជ្ជមាន និងវិជ្ជមានពីប្រព័ន្ធផ្សព្វផ្សាយដើម្បីឱ្យយើងអាចនឹងកំណត់អនាគតរបស់យើងទៅថ្ងៃអនាគត។ កុមារគឺជាសេចក្តីសង្ឃឹមសំរាប់អនាគតរបស់យើង"។

លោកមានប្រសាសន៍ថែមទៀតថា មហាសន្និបាតនេះផ្តល់នូវវេទិការមួយសម្រាប់អង្គការនិងស្ថាប័ន ដែលកំពុងតែធ្វើការជាមួយកុមារ នៅក្នុងប្រទេសកម្ពុជា និងអាស៊ី ឱ្យលើកឡើងអំពីបញ្ហាសិទ្ធិកុមារ និងការព្រួយបារម្ភទាំងឡាយដែលកំពុងប្រឈម។ ការយល់ដឹងអំពីបញ្ហា វានឹងនាំមកនូវចំណេះដឹងដ៏អស្ចារ្យ និងការផ្លាស់ប្តូរនូវផលប្រយោជន៍ចំពោះកុមារទាំងនោះ។

លោកអូមែរ មានប្រសាសន៍ឱ្យដឹងទៀតថា មហាសន្និបាតអាស៊ីនាលើកនេះ នឹងផ្តល់ផលប្រយោជន៍ទាំងកុមារកម្ពុជា ដែលងាយរងគ្រោះ និងប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេស។

លោកនាយករូបនេះ បានបន្តទៀតថា ពាក់ព័ន្ធនឹងឥទ្ធិពលរបស់ប្រព័ន្ធផ្សព្វផ្សាយមកលើកុមារ លោកឪពុកគិតថា វាគឺជាបញ្ហាមិនអាចជៀសវាងបាន។ ស៊ីកនីសជាអង្គការមិនគិតប្រយោជន៍ខាងសាសនាកាតូលិកមួយ ដែលបានជួយអភិវឌ្ឍន៍នូវគម្រោងផ្សព្វផ្សាយគ្រប់កន្លែងដោយពុំរើសអើងសាសនា។ ប្រទេសកម្ពុជាបានចូលជាសមាជិករបស់ស៊ីកនីសក្នុងចំណោម១៤០ប្រទេស កាលពីឆ្នាំ២០០៤។

### កម្មវិធីផ្តល់រង្វាន់

**នៅក្នុងអង្គសន្និបាតនេះ គណៈកម្មការរៀបចំបានផ្តល់រង្វាន់ដល់អ្នកដែលបានផលិតខ្សែភាពយន្តអប់រំខ្លីរយៈពេលមួយនាទីស្តីពីកុមារនៅអាស៊ី និងប្រព័ន្ធផ្សព្វផ្សាយ។ ប្រទេសដែលទទួលរង្វាន់នេះ គឺស៊ីកនីសម៉ាឡេស៊ី ដែលផលិតខ្សែអប់រំខ្លី ដែលមានចំណងជើងថា "ស៊ុបភើមែន" ដែលអប់រំកុមារកុំឱ្យយកតម្រាប់តាមស៊ុបភើមែន ដែលអាចហោះហើរពីអគារមួយទៅមួយអាគារមួយបាន។**




អ្នកចូលរួមស៊ីកនីស ថតរូបជុំគ្នា

Photo : L. Sovanna

# លើកកម្ពស់ធនធានមនុស្ស ដោយបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឡុង សម្ផស្ស**


សកម្មភាពនិស្សិតក្នុងមណ្ឌលរបស់អង្គការ មនុស្សលោកថ្មី ខណ្ឌទួលគោក រាជធានីភ្នំពេញ

Photos : L. Samphors

ការបណ្តុះបណ្តាលវិជ្ជាជីវៈអាចជាផ្នែកមួយនៃការជួយលើកកម្ពស់តម្លៃធនធានមនុស្ស។ នេះជាការរួមចំណែកជួយ សម្រាលបន្ទុករបស់រាជរដ្ឋាភិបាល ក៏ដូចជាការរួមចំណែកជួយដល់យុវជន យុវនារីក្រីក្រ នៅតាមជនបទ ដែលគ្មានលទ្ធភាពក្នុងការបន្តសិក្សាទៅថ្នាក់ឧត្តម។

លោកអៀ វ៉េ នាយកអង្គការមនុស្សលោកថ្មី មានប្រសាសន៍ឱ្យដឹងថា: "អង្គការមនុស្សលោកថ្មីគឺជាអង្គការមនុស្សធម៌មួយនៃប្រទេសអ៊ីតាលី បានធ្វើការដោយស្ម័គ្រចិត្ត មិនសំដៅរកប្រាក់ចំណេញ មិនពាក់ព័ន្ធនឹងនយោបាយ និងដោយទទួលស្គាល់អំពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា។

អង្គការមនុស្សលោកថ្មី កំពុងធ្វើការ ក្នុងខេត្តក្រុងចំនួន៤: ក្រុងភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង និងខេត្តមណ្ឌលគិរី។ អង្គការមនុស្សលោកថ្មីបានចាប់ផ្តើមធ្វើការនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩២ ហើយក៏បានចាប់ផ្តើមអនុវត្តនីគម្រោងរបស់ខ្លួននៅក្នុងខេត្តកំពង់ឆ្នាំងនាឆ្នាំ២០០២។

អង្គការក៏មានទស្សនៈវិស័យ លើការរៀបចំបង្កើតឡើងដើម្បីផ្តល់ដល់មនុស្សគ្រប់ៗរូប ទទួលបាននូវឱកាសស្មើគ្នាក្នុងការអប់រំដ៏សមរម្យស្របទៅតាមតម្រូវខាងកាយសម្បទាន និងសមត្ថភាពពួកគេ។

អង្គការមានគោលបំណង ដើម្បីអភិវឌ្ឍវិស័យលើអប់រំដោយជាពិសេសសំដៅសម្រាប់កុមារ យុវជនស្ត្រី និងជនពិការដោយអង្គការធ្វើការជាដៃគូយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន ក៏ដូចជាប្រជាជនក្នុងសហគមន៍ជនបទ។

លោកនាយកបានបញ្ជាក់ផងដែរថា: "ដោយមើលឃើញពីតម្រូវការរបស់យុវជនខ្មែរ ក្នុងការបន្តការសិក្សា ឱ្យបានខ្ពង់ខ្ពស់ទៅមុខ តាមរយៈការសិក្សានូវជំនាញផ្សេងៗនោះ ទើបអង្គការមនុស្សលោកថ្មីបាន និងកំពុងជួយឧបត្ថម្ភដល់យុវជន និងយុវនារីក្រីក្រ ចំនួន ១៦នាក់ ដែលមកពីបណ្តាខេត្តផ្សេងៗ ដើម្បីឱ្យពួកគេអាចមានលទ្ធភាព ស្វែងរកការងារធ្វើបាននាពេលអនាគត។ កម្មវិធីនេះអាចសម្រេចទៅបាន ដោយសារយើងមានកិច្ចសហការជាមួយនិងមជ្ឈមណ្ឌលបណ្តុះបណ្តាលប្រព័ន្ធព័ត៌មានវិទ្យា ហៅកាត់ (CIST) ផងដែរ"។

អង្គការមនុស្សលោកថ្មី គឺស្ថិតនៅផ្ទះលេខ ១៩ ផ្លូវ ៣១៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក ភ្នំពេញ។

# សួន គីរី : "បើគ្មានជំនួយពីអង្គការ ខ្ញុំគ្មានឱកាសដូចនេះទេ"

កំពុងអង្គុយធ្វើកិច្ចការសាលាជាមួយកុំព្យូទ័រ សួន គីរី ដែលមានអាយុ២១ឆ្នាំ រស់នៅភូមិកន្ទ្រែង ឃុំខុនរ៉ងស្រុកបរិបូរណ៍ខេត្តកំពង់ឆ្នាំង។លោកក៏ធ្លាប់ជាសិស្សនៅវិទ្យាល័យហ៊ុន សែន បរិបូរណ៍ដែរ។

គីរី និយាយ ឱ្យដឹងថា: "នៅក្នុងចំណោមបងប្អូន ៦នាក់ លោកជាកូនទី៤នៅក្នុងគ្រួសារដែលមានជីវ-ភាពខ្វះខាត។ ទោះបីជាយ៉ាងនេះក្តី ក៏លោកខិតខំប្រឹងប្រែងតស៊ូរៀនសូត្រ រហូតដល់ចប់ថ្នាក់ទី១២ ហើយបានប្រលងជាប់នូវសញ្ញាបត្រទុតិយភូមិជាស្ថាពរ កាលពីឆ្នាំ២០០៦ កន្លងទៅនេះ។

ក្រោយពេលប្រលងជាប់ សួន គីរី ក៏ត្រូវបានមជ្ឈ-មណ្ឌលបណ្តុះបណ្តាលប្រព័ន្ធព័ត៌មានវិទ្យាជ្រើសរើសឱ្យចូលរៀនជំនាញខាងប្រព័ន្ធព័ត៌មានវិទ្យា IT ដោយមានកិច្ចសហការ និងជួយឧបត្ថម្ភពីសំណាក់អង្គការមនុស្សលោកថ្មី ការបង់ថ្លៃសិក្សាហើយនិងការស្នាក់នៅ ហូបចុករយៈពេល ២ឆ្នាំ ក្នុងមណ្ឌលរបស់អង្គការមនុស្សលោកថ្មីផ្ទាល់តែម្តង។



លោកបញ្ជាក់ឱ្យដឹងថា សិស្សៗទាំងអស់ដែលមានបំណងចង់រៀន នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលប្រព័ន្ធព័ត៌មានវិទ្យា គឺត្រូវការឆ្លងកាត់ការធ្វើតេស្តសាកល្បងសមត្ថភាព ការធ្វើសម្ភាសន៍ ផ្ទាល់មាត់ និងការវាយតម្លៃទៅលើបញ្ហាជីវភាពគ្រួសាររបស់ខ្លួន ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រ ពីអង្គការណាមួយជាមុន ទើបអាចចូលរៀនបាន។

គីរី បញ្ជាក់ ជាចុងក្រោយថា: "ប្រសិនបើគ្មានការជួយឧបត្ថម្ភពីអង្គការមនុស្សលោកថ្មីនេះទេ ខ្ញុំមិនមានឱកាសដូចពេលនេះទេ"។ ពេលអនាគត សួន គីរី មានបំណងចង់ក្លាយទៅជាអ្នកគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ដែលមានជំនាញយ៉ាងពិតប្រាកដ ១ រូបសម្រាប់ក្រុមហ៊ុនឯកជន ឬស្ថាប័នណាមួយ។







បើកបរល្បឿនហួស ដូចជាយកជីវិតទៅប្រថុយនឹងការស្លាប់

Photo : HIB

# យុវជនប្រឈមមុខនឹងគ្រោះថ្នាក់ចរាចរណ៍ខ្ពស់

**ខាន់ ភីរម្យ**

បើយោងតាមតួលេខ ៦ខែ របស់អង្គការជនពិការអន្តរជាតិ ប្រាប់ឱ្យដឹងថា ក្នុងចំណោមជនរងគ្រោះដោយចរាចរណ៍ភាគច្រើនបំផុតគឺជាយុវជន។

លោកសែម បញ្ញាវុឌ្ឍ អ្នកគ្រប់គ្រងប្រព័ន្ធព័ត៌មានជងរងគ្រោះនិងគ្រោះថ្នាក់ចរាចរណ៍នៃអង្គការជនពិការអន្តរជាតិ មានប្រសាសន៍ថា នៅក្នុងចំណោមជនរងគ្រោះដោយចរាចរណ៍ រយៈពេល ៦ខែ ដើមឆ្នាំ២០០៨នេះ ជនរងគ្រោះដែលមានអាយុចាប់ ពី១៥ដល់២៩ឆ្នាំ ជាក្រុមអាយុដែលមានអត្រាគ្រោះថ្នាក់ចរាចរណ៍ច្រើនជាងគេ។

លោកបញ្ជាក់ថា : "យើងរកឃើញមានគ្រោះថ្នាក់ចរាចរណ៍ ៤០០០ករណី និងជនរងគ្រោះដល់ជីវិតនោះ មានចំនួន ៨០០នាក់ ចំណែកអ្នករបួសគឺមានចំនួន ១២០០០នាក់ នៅក្នុងនោះជនរងគ្រោះដែលស្ថិតនៅក្នុង ក្រុមអាយុពី១៥ ទៅ២៩ឆ្នាំ មានចំនួនរហូតដល់ទៅជិត ៥០% ក្នុងចំណោមជនរងគ្រោះសរុប"។ លោកបន្តទៀតថា ក្រៅពីនេះ ក្រុមអាយុពី៤០ ទៅ៦០ឆ្នាំ វិញ មានចំនួនប្រមាណជា ១៥% ចំណែកភាគរយដែលនៅសល់ ជាក្រុមអាយុផ្សេងទៀត។ លោកបានបន្ថែមថា គ្រោះថ្នាក់ចរាចរណ៍កើតមានគ្រប់វ័យទាំងអស់។ហើយមូលហេតុដែលបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍ទាំងអស់នេះគឺជាង ៥០% គឺវាកើតមានឡើងដោយសារតែការបើកបរហួសល្បឿនកំណត់ ការពិសាគ្រឿងស្រវឹងមាន១៥% ហើយការបើកបរជែងគ្នា ក៏មានចំនួន ១៣%ផងដែរ។

ផ្អែកទៅតាមតួលេខនេះ លោកបញ្ញាវុឌ្ឍ ក៏បានធ្វើការអំពាវនាវដល់ពលរដ្ឋកម្ពុជាទាំងអស់ បើកបរដោយមានការអធ្យាស្រ័យ គោរពច្បាប់ចរាចរណ៍ និងមិនប្រើគ្រឿងស្រវឹង ជាពិសេសយុវជន។

យុវជន ស្ថិតក្នុងវ័យ ២២ឆ្នាំ មួយរូប ដែលអះអាងថាឈ្មោះវាសនានោះ បាននិយាយថា ខ្លួនយល់ថាបើកបរលឿន គឺគ្រោះថ្នាក់។ តែភាគច្រើន រូបគេមិនអាចគេចពីការបើកបរលឿននេះបានទេ ដោយសារ គេចង់បាននូវភាពសង្ហា និងការទាក់ទាញ ជាពិសេសនៅពេលជិះម៉ូតូថ្មី។ វាសនាបន្តថា ជិះម៉ូតូបើកយឺតៗ គឺមិនសូវគេចាប់អារម្មណ៍ទេ ប៉ុន្តែបើបើកបរលឿន ហើយសាហាវបន្តិចនោះ អាចទាក់ទាញគេបាន ពិសេសយុវនារីក្មេងៗ ទាន់សម័យ។

វាសនា បញ្ជាក់ថា: "ជិះយឺត ស៊ាំចិត្តណាស់"។ ជួនកាលនៅពេលដែលគេបើកបរយឺតម្តងៗ ហើយគេឃើញយុវជនផ្សេងៗទៀតបើកវ៉ាគេភ្លាម គឺរូបគេជេរបុគ្គលនោះភ្លាម តែបន្តិចក្រោយមក រូបគេគិតថា បុគ្គលនោះមានម៉ូតូស្អាត និងបើកបរបានលឿនល្អ។ វាសនាក៏បន្ថែមថា នៅក្នុងករណីខ្លះនៅពេលដែលរូបគេបើកបររួមជាមួយនឹងមិត្តភ័ក្តិ។បើបើកបរយឺតៗជាងគេនោះ មិត្តភ័ក្តិគេ ច្បាស់ជានិយាយឱ្យរូបគេថា បើកបរអន់មិនខាន។ វាសនាក៏បញ្ជាក់ទៀតថា: "ពេលបើកបរ ជួនកាលរូបគេជេរខ្ញុំ ជួនកាល ខ្ញុំជេរគេ វាគឺជារឿងធម្មតា។ បើកបរគោរពច្បាប់ពេក មិត្តភ័ក្រថាយើងអន់ ហើយសើកៗ"។

ទាំងនេះគ្រាន់តែជាការអះអាងតាមយោបល់ផ្ទាល់ខ្លួនរបស់វាសនាប៉ុណ្ណោះ។ តែតាមសភាពពិត និងស្ថានភាពចរាចរណ៍សព្វថ្ងៃ ទង្វើបើកបរលឿននេះ គឺប្រឈមមុខនឹងគ្រោះថ្នាក់ខ្លាំងណាស់។

លោកបញ្ញាវុឌ្ឍ បន្ថែមថា ដោយសារតែស្ថានភាពចរាចរណ៍នៅក្នុងប្រទេសកម្ពុជា មានសភាពមមាញឹកខ្លាំងនោះ ការបើកបរមួយដែលមានសុវត្ថិភាពគួរតែមានល្បឿនក្រោម ៣០គីឡូក្រាម នៅក្នុង១ម៉ោង នៅទីក្រុង និងតាមទីប្រជុំជន ហើយចំពោះតាមផ្លូវជាតិវិញ ត្រូវតែមានល្បឿនមិនហួសពី ៨០គីឡូម៉ែត្រ ក្នុងមួយម៉ោងឡើយ ព្រោះបើបើកបរលើសពីល្បឿននេះ អ្នកបើកបរពិបាកនឹងគ្រប់គ្រងយានយន្តបានណាស់។

លោកបានបន្ថែមថា នៅចុងឆ្នាំនេះ ដើម្បីស្វែងរកមូលហេតុពិតប្រាកដនៃគ្រោះថ្នាក់ចរាចរណ៍នោះ គម្រោងរបស់លោក នឹងមានផែនការធ្វើការសិក្សាមួយពីឥរិយាបថរបស់អ្នកបើកបរ។ លោកបញ្ជាក់ថា ការសិក្សានេះនឹងដំណើរការ នៅចុងឆ្នាំ២០០៨ និងដើមឆ្នាំ២០០៩ខាងមុខ នៅក្រោមការឧបត្ថម្ភថវិកាពីបែលហ្សិក និងម្ចាស់ជំនួយឯទៀត។

October-2008.qxd 10/7/2008 10:52 AM Page 10

## បទយកការណ៍

# ជីវិតទុរគតរបស់ជនចាស់ជរានៅជាយរាជធានី ភ្នំពេញ

**ខាន់ ភីរម្យ**

ជនចាស់ជរាដែលមិនមានទីពឹងពំនាក់ នៅជីវិតចុងក្រោយរបស់ពួកគាត់ នៅក្នុងសហគមន៍ សែនសុខ ដែលជាសហគមន៍ក្រីក្រមួយនៅជាយក្រុងភ្នំពេញ កំពុងតែអំពាវនាវស្វែងរកការទំនុកបម្រុង និងការគាំពារពីច្បាប់ ។

នៅក្នុងបរិបទសង្គមកម្ពុជាជនចាស់ជរាជាទូទៅ គឺត្រូវរស់នៅ ក្នុងបន្ទុក និងការថែទាំពីកូនចៅ ប៉ុន្តែជាអកុសល ចំពោះលោកយាយទូច នី និងជនចាស់ជរាក្រីក្រមួយចំនួន ដែលគ្មានសាច់ញាតិ ដែលមិនអាចពឹងពាក់ បានកំពុងជួបនូវការលំបាកមែនទែនដោយសារតែភាពក្រីក្រ ។

លោកយាយទូច នី អាយុ ៧៥ឆ្នាំ រស់នៅក្នុងសហគមន៍ សែនសុខ៦ បានមានប្រសាសន៍ ទាំងសភាពញ័រញាក់ជាមួយនឹងជំងឺគ្រុនថា កាលនៅក្មេងពេញកម្លាំង លោកយាយមានមុខរបរដើររើសអេតចាយដើម្បីចិញ្ចឹមកូនប្រុសមួយរូបដល់ធំពេញវ័យ ហើយដល់ពេលគាត់ចាស់ កូនប្រុសបានជួយទំនុកបម្រុងគាត់វិញដែរ ។ ប៉ុន្តែជាអកុសល កូនប្រុសរបស់គាត់បានស្លាប់ដោយសារជំងឺកាលពីឆ្នាំ២០០៥ ជាហេតុត្រូវធ្វើឱ្យគាត់បាត់បង់ការទំនុកបម្រុង ហើយថែមទាំងត្រូវទទួលបន្ទុកចិញ្ចឹមចៅ ដែលមានវ័យពី ៣ឆ្នាំ ទៅដល់ ៧ឆ្នាំ ដល់ទៅ ៣នាក់ទៀត ។ លោកយាយត្រូវបង្ខំចិត្តវិលមករបរចាស់ម្តងទៀតដើម្បីចិញ្ចឹមចៅៗរបស់គាត់ បើទោះជាគាត់ ស្ថិតក្នុងវ័យចាស់ជរាដែលមិនអាចធ្វើឱ្យរូបគាត់ប្រកបរបរនេះដូចកាលពីក្មេងក៏ដោយ ។

លោកយាយមានប្រសាសន៍ថា: "ខ្ញុំចាស់មែន ។ តែបើខ្ញុំគិតថា ខ្ញុំចាស់ ហើយមិនខំប្រឹងប្រែង តើចៅនិងក្រពះខ្ញុំបានអ្វីហូប" ?

រៀងរាល់ថ្ងៃ លោកយាយត្រូវដើរមិនតិចជាង ៥០ គ.មទេ ដើម្បីរើសអេតចាយ ពីផ្ទះខ្ទមរបស់លោកយាយឆ្ពោះមកកាន់ទីក្រុងភ្នំពេញដែលជាទីប្រជុំ ។ លោកយាយត្រូវចេញដំណើរពីផ្ទះ ចម្ងាយប្រមាណ ១១គ.មពីទីក្រុង និងដើរសព្វកន្លែងស្វែងរកសំបកកំប៉ុង ឧបករណ៍ប្រើប្រាស់ធ្វើពីប្លាស្ទិកដើម្បីលក់ជាថ្នូរនឹងទឹកប្រាក់ពី៨០០០រៀល ទៅ១០០០០រៀល ប៉ុណ្ណោះ នៅក្នុងមួយថ្ងៃ ។

ជីវិតរបស់លោកយាយ មិនខុសពីជីវិតរបស់លោកតានេន រ៉េត ដែលមានអាយុ ៧៦ឆ្នាំហើយ ប៉ុន្តែលោកតាកំពុងតែស៊ីឈ្នួលគេមើលគោ និងពពែ ជាថ្នូរនឹងប្រាក់ខែ ៥០០០០រៀល ។ លោកតាមានកូន និងចៅនឹងគេដែរ តែពួកគេសុទ្ធតែជាអ្នកក្រីក្រស៊ីឈ្នួលគេដើម្បីរស់ដែរ ។

លោកតាមានប្រសាសន៍ថា រស់នៅជាមួយនឹងភាពក្រីក្រ មានការលំបាកណាស់ និងកាន់តែធ្វើឱ្យគាត់កាន់តែឯកោ ។ លោកតាបន្ថែមថា កូនៗរបស់គាត់មិនមែន មិនរវល់នឹងគាត់នោះទេ ប៉ុន្តែដោយសារតែភាពក្រីក្រ ពួកគេជួបនឹងការលំបាកនៅក្នុងការជួយទំនុកបម្រុងគាត់ដែរ ។

លោកតាមានប្រសាសន៍បញ្ជាក់ថា: "វ័យជរាកំពុងតែធ្វើឱ្យខ្ញុំកាន់តែវេទនា និងក្រីក្រ ។ ខ្ញុំត្រដរចិញ្ចឹមខ្លួនឯង ។ រីឯពួកគេដែលធ្វើជាខ្ញុំគេដែរនោះក៏ត្រដរចិញ្ចឹមខ្លួនឯង និងកូនរបស់គេដែរ" ។

លោកស្រីសែម ម៉េងលី ប្រជាពលរដ្ឋនៅក្នុងសហគមន៍សែនសុខមួយរូបដែរនោះ មានប្រសាសន៍ថា ភាពក្រីក្រ គឺជាកត្តាមួយដ៏សំខាន់ដែលជំរុញឱ្យជនចាស់ជរានឹងកាន់តែរងគ្រោះ ។ ម្នាក់ៗសុទ្ធតែត្រដរដើម្បីរស់ដូចគ្នា ។

លោកស្រីបានបញ្ជាក់ថា: "ខ្ញុំមានមុខរបរ ។ ខ្ញុំមានការងារធ្វើ ។ ខ្ញុំអាចផ្គត់ផ្គង់ឪពុកម្តាយខ្ញុំបាន ។ ចុះអ្នកក្រីក្រដែលមិនមានការងារធ្វើ?" ។

លោកយាយកង ឆែងួន មានអាយុ ៦០ឆ្នាំ ដែលជាម្តាយរបស់លោកស្រីសែម ម៉េងលី មានប្រសាសន៍ថា ជីវិតលោកយាយ និងស្វាមី មានសំណាងគ្រាន់បើជាងបណ្តាជនចាស់ជរាមួយចំនួន នៅក្នុងសហគមន៍ដោយសារគាត់មានកូនៗ ជាអ្នកផ្គត់ផ្គង់ខ្លះ ។ លោកយាយអះអាងថា លោកយាយមានកូនទាំងអស់ ៧នាក់ ហើយស្វាមីលោកស្រីកំពុងតែមានជំងឺ ប៉ុន្តែដោយសារតែ កូនៗរបស់គាត់ មានការងារធ្វើនៅក្នុងទីក្រុងភ្នំពេញនោះ គឺគាត់មានសំណាងជាងអ្នកជិតខាងគាត់បន្តិច ។

លោកយាយក៏ប្រាប់ឱ្យដឹងថា មូលហេតុដែលជំរុញឱ្យពួកគាត់ មានស្ថានភាពប្រសើរយ៉ាងដូច្នេះនោះ គឺដោយសារតែលោកយាយ និងស្វាមីសុទ្ធតែជំរុញកូនៗឱ្យទៅសាលារៀនបានទាំងអស់គ្នា បើទោះបីជាគាត់ក្រីក្រ មានមុខរបរជាជាងប៉ះកង់ម៉ូតូដែលរកចំនួលបានតែបន្តិចបន្តួចក្តី ។

លោកយាយ អះអាងថា: "បើកុំតែខ្ញុំឱ្យកូនរបស់ខ្ញុំបានទៅរៀននោះ ខ្ញុំប្រហែលជាមានវាសនាពុំខុសពីចាស់ៗមួយចំនួនក្នុងភូមិប៉ុន្មានទេ" ។

លោកកែវ ចន្ថា ជាប្រធានអង្គការទ្រទ្រង់ជនចាស់ជរាកម្ពុជាដែលកំពុងតែមានសកម្មភាពទ្រទ្រង់ជនចាស់ជរា នៅក្នុងសហគមន៍សែនសុខ ចំនួន៤៥នាក់ មានប្រសាសន៍ថា ជាទូទៅ នៅក្នុងប្រទេសកម្ពុជា ក្រៅពីគ្រួសារ ជនចាស់ជរាហាក់ត្រូវបានគេបំភ្លេចចោល ។ លោកបញ្ជាក់ថា អង្គការដែលជួយកុមារ និងកម្មវិធីផ្សេងៗនៅក្នុងប្រទេស មានរាប់រយ តែសម្រាប់អង្គការ ដែលធ្វើការសម្រាប់ជនចាស់ជរាគឺមិនមានច្រើនឡើយ ។

លោកពោលថា : "កុមារគេគិតថា ក្លាយជាទំពាំងស្នងឫស្សី ចុះចំណែកចាស់ជរាវិញ?"

លោកបានបញ្ជាក់ថា ថ្វីបើពួកគេជាអ្នកក្រីក្រមែន ប៉ុន្តែបើគិតតាមអាយុរបស់ពួកគាត់ គឺពួកគាត់ពុំគួរធ្វើការងារអ្វីទៀតទេ គឺពួកគេគួរទទួលបានការរស់នៅដោយសមរម្យ ដែលស្របតាមសិទ្ធិរបស់ពួកគេ ដោយមាននូវអាហារបរិភោគគ្រប់គ្រាន់ ការថែទាំសុខភាព ជម្រក ហើយអ្វីសំខាន់ជាងនេះទៅទៀតនោះ គឺគួរតែមានច្បាប់មួយ ដើម្បីធានាការទទួលខុសត្រូវមួយស្របច្បាប់ពីរដ្ឋក្នុងអំឡុងពេលដ៏ខ្លីនៃជីវិតចុងក្រោយរបស់ពួកគេ ។

យ៉ាងណាមិញ លោកមាស ស៊ុនរី ប្រធានសមាគមជួយជនចាស់ជរា ក្នុងឃុំអរិយក្សត្រ ខេត្តកណ្តាល មានប្រសាសន៍ថា សមាគមរបស់ពួកគាត់ អាចរស់បាន ដោយសារតែមានការគាំទ្រពីសមាជិករបស់សហគមន៍តែប៉ុណ្ណោះ ។ លោកក៏យល់ស្របជាមួយនឹងលោកកែវ ចន្ថាដែរ ចំពោះគំនិតស្តីពីការបង្កើតច្បាប់ដើម្បីការពារដល់ជនចាស់ជរា ។ លោកក៏បានបញ្ជាក់ថា : "ច្បាប់ជាកិច្ចធានាស្របច្បាប់សម្រាប់ជីវិតចុងក្រោយរបស់ពួកគេ" ។

លោកយាយទូច នី មានប្រសាសន៍ថា លោកយាយជួបប្រទះភាពវេទនា និងភាពក្រីក្រនោះ អស់រយៈពេលជាង ៧០ឆ្នាំហើយ ។ នៅឆាកជីវិតចុងក្រោយ លោកយាយចង់បានជីវភាពមួយសមរម្យ និងមានជំនួយពីរដ្ឋ ។ លោកយាយក៏បញ្ជាក់ថា : "ខ្ញុំវេទនាឆ្អែតឆ្អន់ហើយ ហើយក្នុងឆាកជីវិតចុងក្រោយ ខ្ញុំចង់ឃើញរដ្ឋឧបត្ថម្ភខ្ញុំ" ។

លោកតានេន រ៉េត អំពាវនាវថា: "ខ្ញុំមិនប្រាថ្នាអ្វីធំដុំទេ ដោយសារខ្ញុំគឺជាអ្នកក្រីក្រ ប៉ុន្តែនៅក្នុងជីវិតចុងក្រោយនេះ ខ្ញុំចង់បានកន្លែងមួយដែលមានការជួយឧបត្ថម្ភជាអាហារ ទីជម្រក ការថែទាំសុខភាព ហើយជាងនេះទៅទៀតនោះ គឺច្បាប់ការពារខ្ញុំ" ។

រហូតមកដល់ពេលនេះ ជនចាស់ជរាពិតប្រាកដនៅក្នុងប្រទេសកម្ពុជា មិនទាន់ដឹងនៅឡើយទេដោយសារលទ្ធផលជំរឿនថ្មីដែលគេធ្វើនៅក្នុងឆ្នាំ២០០៨នេះនៅមិនទាន់ចេញជាផ្លូវការនៅឡើយ ។ ប៉ុន្តែបើយោងទៅតាមជំរឿនកាលពី១០ ឆ្នាំមុន នោះ នៅក្នុងចំណោមប្រជាពលរដ្ឋ ចំនួនជាង ១១លាននាក់ ចំនួនជនចាស់ជរា ដែលមានអាយុចាប់ពីជាង ៦០ឆ្នាំឡើងនោះ គឺមានចំនួន ៥,៣% ។ ថ្វីត្បិតតែចាស់ជរានៅប្រទេសកម្ពុជា មិនទាន់មានច្បាប់សម្រាប់ធានាការពារដល់ពួកគាត់ ប៉ុន្តែរដ្ឋាភិបាលមិនបានព្រងើយកន្តើយចំពោះពួកគាត់ទាំងស្រុងដែរ ។ រដ្ឋាភិបាលបានបង្កើតនូវកញ្ចប់ថវិកាសមធម៌មួយសម្រាប់ធានា និងផ្តល់សេវាថែទាំសុខភាពដល់ពួកគេដោយមិនគិតប្រាក់ឡើយ ។



Photo : L. Samphors

ត្រូវតែយកចិត្តទុកដាក់ចាស់ជរាដើម្បីសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ

### ស្ថានភាពរបស់ជនចាស់ជរានៅសហគមន៍សែនសុខ

**ផ្ទះមួយខ្នង មានទំហំប្រមាណជា ៣ម៉ែត្រ ៤ជ្រុង មានជញ្ជាំងធ្វើពីបន្ទះថែប ដំបូលប្រក់ស្លឹកត្នោត និងរនាបធ្វើពីបន្ទះឫស្សីនៅលើប្រឡាយទឹកមួយកន្លែងនៅក្នុងសហគមន៍សែនសុខ សង្កាត់ឃ្មួញ ខណ្ឌឫស្សីកែវ គឺជាផ្ទះរបស់លោកយាយទូច នី អាយុ ៧៥ឆ្នាំ ដែលកំពុងតែអំពាវនាវស្នើសុំជំនួយនៅក្នុងនាមជនចាស់ជរាក្រីក្រ នៅក្នុងប្រទេសកម្ពុជាមួយរូប។ លំនៅដ្ឋានរបស់លោកយាយទូច នី មានស្ថានភាពមិនខុសពីលំនៅដ្ឋានរបស់បណ្តាជនក្រីក្រនានានៅក្នុងសហគមន៍នេះនោះទេ។ សហគមន៍នេះជាសហគមន៍ក្រីក្រមួយដែលត្រូវបានអាជ្ញាធរក្រុងភ្នំពេញរុះរើពីម្តុំប៊ូឌិញ ទីក្រុងភ្នំពេញ។ ក្រៅពីភាពក្រីក្រហើយនោះ បញ្ហាដែលកំពុងតែកើតមាននៅក្នុងសហគមន៍នេះទៀតនោះគឺជំងឺអេដស៍។ ពួកគាត់ភាគច្រើនរស់នៅជាមួយនឹងកម្រិតប្រាក់ចំណូលតិចជាងមួយដុល្លារនៅក្នុងមួយថ្ងៃ។**

### អង្គការទ្រទ្រង់ជនចាស់ជរាកម្ពុជា

**គឺជាអង្គការក្រៅរដ្ឋាភិបាលនៅក្នុងស្រុកមួយដែលបង្កើតឡើងនៅក្នុងឆ្នាំ២០០០ ដើម្បីជួយដល់ជនចាស់ជរា ដែលរស់នៅជាមួយនឹងកូនដែលមានជីវភាពក្រីក្រជនចាស់ជរាគ្មានទីពំនាក់ ហើយមិនអាចធ្វើការកើតជនចាស់ជរាដែលទទួលការរំលោភបំពានពីកូនៗ របស់ពួកគាត់។ អង្គការនេះមានគោលបំណងធ្វើការតស៊ូមតិ និងការពារសិទ្ធិរស់នៅរបស់ជនចាស់ជរានៅក្នុងប្រទេសកម្ពុជា។ លោកកែវ ចន្ថា ប្រធានអង្គការទ្រទ្រង់ជនចាស់ជរាកម្ពុជា មានប្រសាសន៍ថា គោលបំណងនៃការបង្កើតអង្គការនេះ គឺដើម្បីធ្វើការតស៊ូមតិនៅក្នុងប្រទេសដើម្បីជំរុញឱ្យបណ្តាជនចាស់ជរានានានៅក្នុងប្រទេសកម្ពុជាទទួលបានការគាំពារពីច្បាប់ និងទទួលបានការរស់នៅមួយដែលមានការទំនុកបម្រុងជាម្ហូបអាហារ ទីជម្រក និងការថែទាំសុខភាពរបស់ពួកគាត់។ លោកបញ្ជាក់ថា : "ថ្វីបើគាត់ចាស់មិនអាចធ្វើការជួយសង្គមកើត តែកុំភ្លេច គាត់ក៏ជាសមាជិកសង្គមម្នាក់ និងធ្លាប់ជួយសង្គមបានច្រើនដែរ។ ពួកគាត់គួរតែទទួលបានការការពារ និងការថែទាំសម្រាប់ជីវិតចុងក្រោយរបស់ពួកគាត់"។**

October-2008.qxd 10/7/2008 10:52 AM Page 12

## កសិកម្ម

# ថ្នាំកំចាត់សត្វល្អិត បែបធម្មជាតិ

**ផាត សំភី**

តាមប្រភពពីអង្គការ សេដាក ជំនាញខាងកសិកម្ម បានឱ្យដឹងថា:

ថ្នាំពុលផ្សំពីរុក្ខជាតិគឺជាមធ្យោបាយសម្រាប់កំចាត់ជំងឺ និងសត្វល្អិតលើដំណាំមួយយ៉ាងសំខាន់។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ការប្រើថ្នាំពុលផ្សំពីរុក្ខជាតិ អាចទទួលបានជោគជ័យអាស្រ័យលើចំណេះដឹងបទពិសោធន៍ដែលមានកន្លងមក និងការជ្រើសរើសរុក្ខជាតិយកមកប្រើប្រាស់បានសមរម្យរបស់កសិករផ្ទាល់។ រុក្ខជាតិដែលអាចយកមកប្រើធ្វើជាថ្នាំពុលសម្លាប់សត្វល្អិតបាន ត្រូវមានលក្ខណៈល្វីង ចត់ ឆ្អួល ក្រពុល ហិរ ឬពុលតែម្តង។



Photo : CEDAC

ជាតិល្វីងមានដូចជា ស្តៅ និងវល្លិពេជ្យ។ ជាតិពុលគឺគ្រាប់ស្លែង ឬសំបកកន្ទួត។ ជាតិហិរមានម្ទេស។ ជាតិឆ្អួល គឺមានថ្នាំជក់ ខ្ទឹមបារាំង ខ្ទឹមស ម្រះព្រៅ និងពួកជីរ។ ជាតិក្រពុលមានល្ហុង និងទៀប។

ការប្រើប្រាស់ថ្នាំពុលពីធម្មជាតិ ជាជម្រើសមួយល្អសម្រាប់ប្រជាកសិករ ប្រសើរជាជាងការប្រើប្រាស់ថ្នាំពុលគីមី ពីព្រោះថា វត្ថុធាតុដើមសម្រាប់ធ្វើថ្នាំពុលផ្សំពីរុក្ខជាតិ គឺអាចរកបានដោយងាយក្នុងភូមិស្រុកដោយមិនចំណាយថវិកា ហើយកសិករក៏អាចទទួលយកទៅធ្វើប្រើបាន ដោយពុំត្រូវការបច្ចេកទេសខ្ពស់ប៉ុន្មានទេ។ រុក្ខជាតិដែលប្រើ សម្រាប់ធ្វើថ្នាំពុលសម្លាប់សត្វល្អិត ភាគច្រើន គេអាចប្រើបានគ្រប់ផ្នែកទាំងអស់មាន(ឬស ដើម សំបក ស្លឹក ផ្លែ គ្រាប់) និងប្រើបានទាំងនៅស្រស់និងនៅស្ងួត។ វាមិនបន្សល់ជាតិពុល នៅក្នុងបរិស្ថាន និងផលដំណាំយូរឡើយ។ វាក៏មិនធ្វើធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកបរិភោគ ក៏ដូចជាអ្នកប្រើប្រាស់ដែរ ដោយសារជាតិពុលរបស់វា ខ្សោយជាងថ្នាំគីមី។ ថ្នាំពុលផ្សំពីរុក្ខជាតិ ច្រើនប្រើដើម្បីបណ្តេញសត្វល្អិត និងថែមទាំងអាចបង្អាក់ការលូតលាស់ និងការបន្តពូជរបស់ពួកវាទៀត។ ថ្នាំពុលនេះមិនត្រឹមតែប្រើបណ្តេញសត្វល្អិតប៉ុណ្ណោះទេ គឺថែមទាំងអាចប្រើធ្វើជាជីឱ្យដំណាំដុះ លូតលាស់បានល្អផងដែរ។

ទោះបីជាថ្នាំពុលដែលផ្សំអំពីរុក្ខជាតិមាននូវគុណសម្បត្តិច្រើន ប៉ុន្តែវាក៏បង្កការលំបាកខ្លះៗដែរ។ វាមានជាតិពុលខ្លាំងដែរ ដូច្នេះការប្រើប្រាស់វាគឺត្រូវតែប្រុងប្រយ័ត្ន (ការកូរ និងលាយ ត្រូវតែប្រយ័ត្នកុំឱ្យខ្ទាតត្រូវមាត់ និងត្រូវប្រើម៉ាសការពារផង)។ ថ្នាំពុលនេះអាចបំពុលសត្វដែរ ដូចជាត្រី ដូច្នេះត្រូវប្រយ័ត្ន។ ម្យ៉ាងទៀត វាចំណាយពេលយូរក្នុងការផលិត និងពិបាកផលិតច្រើនសម្រាប់ដីទំហំធំ។

## បរិស្ថាន

### ថាមពលព្រះអាទិត្យ

ពេលសព្វថ្ងៃនេះ ការប្រើប្រាស់ថាមពលបានដាក់សំពាធ យ៉ាងខ្លាំងទៅលើបរិស្ថាន ជាមួយនឹងការបំពុលផ្សេង ក្លិន និងសម្លេង។



Photo : Local Capacity Builder

ដូច្នេះបន្ទះថាមពលពន្លឺព្រះអាទិត្យនឹងជាជម្រើសមួយ សម្រាប់ផលិតអគ្គិសនី ដែលមិនបំពុលដល់បរិស្ថាន និងមិនចំណាយលុយទិញប្រេង។

លោកគង់ ផារិទ្ធ ជាប្រធាននៃអង្គការអ្នកកសាងសមត្ថភាព មានប្រសាសន៍ថា ដោយមានការជួយឧបត្ថម្ភពីអង្គការសហប្រជាជាតិ ដើម្បីកិច្ចការអភិវឌ្ឍន៍ លោកបាននាំចូលបន្ទះពន្លឺព្រះអាទិត្យ ជាបច្ចេកវិជ្ជាជប៉ុនតាំងពីឆ្នាំ២០០៦។ ការនាំចូលនេះគឺដោយសារមានសំណូមពរពីបងប្អូនប្រជាពលរដ្ឋ នៅពេលឃើញលោកផលិតកង់ ដែលដើរ ដោយថាមពលពន្លឺព្រះអាទិត្យជាលើកដំបូង។

ថាមពលពន្លឺព្រះអាទិត្យនេះ ក៏អាចប្រើប្រាស់បានគ្រប់ឧបករណ៍អគ្គិសនីទាំងអស់ គ្រាន់តែឧបករណ៍ស៊ីភ្លើងខ្លាំង ត្រូវប្រើបន្ទះបន្លឺច្រើន។ ប៉ុន្តែតួយ៉ាងទូរទស្សន៍ពណ៌ ១៤អ៊ីង រួមនឹងអំពូល ៤-៥ ទៀត គេអាចតម្លើងជាបន្ទះថាមពល ៨០វ៉ាត់ ដែលត្រូវចំណាយ ៩០០ដុល្លារ ក្នុងមួយឈុត។

ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យនេះ គឺអាចធ្វើឱ្យគេចំណេញថាមពល ពី១០ដង ទៅ ២០ដង ធៀបនឹងថាមពលផ្សេងៗទៀត ហើយរយៈពេលប្រើបន្ទះ អាចបានពី២៥ឆ្នាំ ទៅ៣០ឆ្នាំ ប៉ុន្តែផលលំបាកមួយតម្លើងដំបូងត្រូវចំណាយអស់ច្រើន។

លោកគង់ ផារិទ្ធ ក៏បញ្ជាក់ថា ប្រសិនបងប្អូនប្រជាពលរដ្ឋចាប់អារម្មណ៍ លោកអាចថ្លៃប្រឹឌិតតម្លើងជូន ដោយធ្វើគណនាឱ្យគាត់ចំណាយតិចប្រើប្រាស់បានសមរម្យ និងមានការសន្សំសំចៃខ្ពស់បំផុត។



## សុខភាព

# ការសង្គ្រោះបឋមចាំបាច់សម្រាប់ជនរងគ្រោះថ្នាក់ភ្លាមៗ

**ខាន់ ភីរម្យ**

លោកស្រីវេជ្ជបណ្ឌិត ឆាយ លក្ខិណា សាស្ត្រាចារ្យនៅឯសកលវិទ្យាល័យបញ្ញាសាស្ត្រ មានប្រសាសន៍ថា ការសង្គ្រោះបឋមអាចជាចំណេះដឹងមួយ ដែលមនុស្សគ្រប់គ្នា គួរតែមានការយល់ដឹង ដើម្បីបង្ការនៅពេលនរណាម្នាក់ ដែលកំពុងតែមានគ្រោះថ្នាក់ដោយចៃដន្យភ្លាម ហើយត្រូវការជំនួយជាបន្ទាន់។

លោកស្រីបានបញ្ជាក់ថា: "មនុស្សម្នាក់ៗ អាចនឹងមានគ្រោះថ្នាក់ដល់ជីវិត ប្រសិននៅពេល ដែលគេមានបញ្ហាសុខភាពភ្លាមៗ ហើយគ្មានអ្នកសង្គ្រោះទាន់ពេលវេលា។ ជំនាញសង្គ្រោះបឋមគឺអាចជួយជីវិតមនុស្សភ្លាមៗ"។

លោកស្រីឆាយលក្ខិណា ប្រាប់ឱ្យដឹងដែរថា មនុស្សម្នាក់ៗអាចនឹងជួបនូវបញ្ហាសុខភាព និងឈានដល់សន្លប់ភ្លាមៗនៅតាមផ្លូវ នៅកន្លែងធ្វើការ ឬកន្លែងសាធារណៈនានា ដោយសារខ្យល់គរ កង្វះជាតិស្កររ ខ្វះជាតិកាល់ស្យូម ឬចលនាឈាមដើរមិនស្រួល។ ដូច្នេះប្រសិនបើពួកគេពុំមានជំនួយ ឬការសង្គ្រោះជំហានដំបូងភ្លាមទេនោះ ពួកគេអាចនឹងមានគ្រោះថ្នាក់ដល់ជីវិតបាន។

លោកស្រីបញ្ជាក់ថា: "ការសង្គ្រោះបឋមនេះត្រូវធ្វើឱ្យអ្នកជំងឺដឹងខ្លួន ប៉ុន្តែទោះជាយ៉ាងណា ត្រូវតែបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យដែរ"។

លោកស្រីឆាយ លក្ខិណា រៀបរាប់ថា ដើម្បីឱ្យជនរងគ្រោះដឹងខ្លួនបានគឺត្រូវឱ្យគេសម្រាកឱ្យត្រង់ខ្លួនដោយក្បាលទាបជាងដងខ្លួនបន្តិច ហើយនៅជុំវិញជនរងគ្រោះ ត្រូវឱ្យមានបរិយាកាសល្អ មានខ្យល់ចេញចូល ដើម្បីឱ្យអុកស៊ីសែនអាចរត់ទៅចិញ្ចឹមខួរក្បាលបានគ្រប់គ្រាន់។ បន្ទាប់មក យើងត្រូវតែធ្វើម៉ាស្សាសព្វដងខ្លួន។ បើអ្នកជំងឺនៅមិនទាន់ដឹងខ្លួនទៀត ត្រូវធ្វើចលនាដល់បេះដូង ដោយសង្កត់សន្ទះទ្រូងបីដង រួចផ្លុំមាត់ម្តង។ ប៉ុន្តែការសង្កត់នោះត្រូវតែមានការប្រយ័ត្នប្រយែងខ្ពស់ ព្រោះថាទង្វើនេះអាចឱ្យអ្នកជំងឺបាក់ឆ្អឹង និងមានគ្រោះថ្នាក់។



Image : DR

លោកស្រីឆាយ លក្ខិណា មានប្រសាសន៍សង្កត់ធ្ងន់ថា នៅពេលដែលសង្គ្រោះរួចរាល់ហើយនោះ ទោះបីអ្នកជំងឺដឹងខ្លួន ឬមិនដឹងខ្លួនក៏ដោយ ត្រូវប្រញាប់ប្រញាល់បញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យជាបន្ទាន់ដែរ។ ការសង្គ្រោះបឋមគ្រាន់តែអាចជួយអ្នកជំងឺនៅក្នុងគ្រាអាសន្នតែប៉ុណ្ណោះ។

ជាចុងក្រោយ លោកស្រី ប្រាប់ថា ជំនាញសង្គ្រោះបន្ទាន់ ឬសង្គ្រោះបឋមនេះមិនសូវជាពិបាកប៉ុន្មានទេ បើសិនយើងបានទទួលការអប់រំខ្លះនោះ។

### មនុស្សជាច្រើនស្លាប់ដោយមហារីកស្បែក

អង្គការសុខភាពពិភពលោកបានអះអាងថា មួយឆ្នាំៗ មានមនុស្សប្រមាណ ៦០០០០ នាក់ បានស្លាប់ដោយសារតែជំងឺមហារីកស្បែក។ ប្រភពដដែលនោះ បានឱ្យដឹងថា មូលហេតុនៃការស្លាប់ភាគច្រើនបណ្តាលមកពីឥទ្ធិពលនៃការរងនឹងពន្លឺកាំរស្មីអុលត្រាវីយ៉ូឡេ ដែលធ្វើឱ្យស្បែកនោះពកហើមរហូត មើលមិនធូរស្បើយ រហូតដល់អ្នកជំងឺបាត់បង់ជីវិត។ ប៉ុន្តែតាមការសិក្សាមួយរបស់អ្នកវិទ្យាសាស្ត្រជនជាតិព័រទុយហ្គាល់ ដកស្រង់ដោយវ៉េបសាយទ័របាន ឱ្យដឹងថា ការប្រែប្រួលនៃហ្សែនខ្លាំងក៏ជាហេតុបណ្តាលកើតជំងឺនេះផងដែរ។ ការវិភាគទៅលើគំរូឈាមរបស់អ្នកស្ម័គ្រចិត្តចំនួន ១០៥៣នាក់ ដោយរួមទាំងអ្នកជំងឺមហារីកស្បែក ១៦១នាក់ និងអ្នកដែលមានសុខភាពល្អចំនួន ៨៩២នាក់ បានឱ្យដឹងផងដែរថា មនុស្សដែលមានការរីកលូតលាស់របស់ហ្សែនខុសពីប្រក្រតីនោះ គឺមានករណីស្បែក ហើម និងរលាកធ្ងន់ធ្ងរ។

### ជំងឺរលាកទៅលើប្រព័ន្ធទឹកនោម



Photo : P. Samphy

តាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិត ហែម សុខហន នៅមន្ទីរពេទ្យកុមារជាតិបានឱ្យដឹងថា:

ជំងឺរលាកតម្រងនោម គេឃើញមានកើត នៅលើកុមារីពី៣% ទៅ៥% និងកុមារាតែ ១%ប៉ុណ្ណោះ។ ក្មេងស្រីកើតច្រើន ជាងក្មេងប្រុស ដោយសារផ្លូវពីប្លោកនោមចេញមកខាងក្រៅខ្លីជាងក្មេងប្រុស និងមិនទាន់ចេះធ្វើអនាម័យឱ្យបានត្រឹមត្រូវ។ ជំងឺនេះបង្កឡើងដោយពពួកបាក់តេរី ឬវីរុស។ ជំងឺរលាកផ្លូវទឹកនោមចែកចេញជាបីធំៗ រលាកតម្រងនោម រលាកប្លោកនោម និងរលាកមិនមានរោគសញ្ញា។

ជំងឺរលាកតម្រងនោម គឺមានរោគសញ្ញាមួយចំនួនដូចជាកុមារឈឺពោះ ជួនកាល ក៏ឈឺនៅចំកណ្តាល និងជួនកាលឈឺសងខាង។ កុមារមានក្តៅផង និងចង្អោរផង។ កុមារមិនឃ្លានអាហារ ហើយចេះតែស្រកគីឡូ។ រលាកតម្រងនោម គឺអាចបណ្តាលមកពីមេរោគដែលជ្រៀតចូលតាមរយៈផ្លូវដង្ហើម។

ចំណែករលាកប្លោកនោម ក្មេង ច្រើននោមទាស់ៗ នោមញឹកញាប់ តែបន្តិចៗ។ ទឹកនោម វាមានក្លិនប្លែកពីធម្មតា។ ប៉ុន្តែមិនមានក្តៅខ្លួនទេដែលធ្វើឱ្យឪពុកម្តាយមានការធ្វេសប្រហែស។ ចំណែកឯមួយទៀត គឺរលាកផ្លូវទឹកនោម តែមិនមានរោគសញ្ញាអ្វីទេ ដែលជំងឺនេះបណ្តាលមកពីការជ្រៀតចូលពីមេរោគមកពីផ្លូវលាមក។

ដើម្បីព្យាបាលជំងឺផ្លូវទឹកនោម ឱ្យមានប្រសិទ្ធភាព យើងត្រូវតែយកអ្នកជំងឺទៅជួបជាមួយវេជ្ជបណ្ឌិតជំនាញ ដើម្បីពិនិត្យសុខភាពឱ្យបានទៀងទាត់ ធ្វើរោគវិនិច្ឆ័យ ហើយនិងព្យាបាលឱ្យបានត្រឹមត្រូវជាពិសេសជំងឺ ដែលមិនមានរោគសញ្ញា គឺវេជ្ជបណ្ឌិតអាចយកទឹកនោមទៅពិនិត្យ ពីព្រោះថា បើយើងចេះតែបណ្តោយ មិនបានព្យាបាលឱ្យបានត្រឹមត្រូវ ការវិវត្តន៍របស់វា នឹងមានយឺតៗ និងស្ងាត់ស្ងៀម រហូតដល់កើតជាដំបៅរលួយតែម្តង។

**ផាត សំភី**

October-2008.qxd 10/7/2008 10:52 AM Page 14






Photo : L. Samphors

# អាជីពគំនូរកំពុងរីកចម្រើនឡើង ស្របនឹងវិស័យទេសចរណ៍

**ខាន់ ភីរម្យ**

ជាមួយនឹងជំនាញគំនូរ វិចិត្រករ វ័យក្មេងមួយរូប និយាយថា មុខរបរវិចិត្រកររបស់ខ្លួនធ្វើឱ្យគេអាចចិញ្ចឹមខ្លួន និងគ្រួសារមួយបានយ៉ាងសមរម្យ ។

លោកឈុំ ចាន់ណា អាយុ ២៣ឆ្នាំ ជាវិចិត្រករ វ័យក្មេងរូបនេះ ដែលបានអភិវឌ្ឍខ្លួនពីការសិក្សានូវជំនាញគូរគំនូរ នៅអង្គការពន្លឺសិល្បៈ និយាយថា កាលពីអតីតកាលគាត់គឺជាយុវជនមួយរូប ដែលបានសិក្សា បន្តិចបន្តួចទេ ហើយគ្មានមុខរបរអ្វីច្បាស់លាស់ឡើយ ប៉ុន្តែនៅពេលនេះ គាត់ជាវិចិត្រករមួយរូប ដែលអាចរកប្រាក់ចំណូលបានល្មមគ្រប់គ្រាន់ ដើម្បីចិញ្ចឹមខ្លួនឯង និងគ្រួសារបានតាមរយៈជំនាញគំនូរនេះ ។

ចាន់ណា បានរៀបរាប់ប្រាប់ថា លោករៀនសាលាចំណេះទូទៅនៅត្រឹមតែថ្នាក់ទី៨ទេ ហើយក៏បានឈប់រៀនរហូត ។ ប៉ុន្តែក្រោយមក លោកចូលរៀនភ្លេង ហើយក៏បានចាប់អារម្មណ៍រឿងគំនូរវិញ ។ សព្វថ្ងៃនេះលោកកំពុងបន្តរៀនជំនាញនេះតទៀត ដោយគិតរហូតមក ដល់ពេលនេះ គឺលោកបានរៀនជំនាញនេះបានរយៈពេល ៥ឆ្នាំហើយ ។ តែលោកបានចេញរកប្រាក់តាមរយៈការលក់គំនូរនេះ ចាប់តាំងពីលោកទើបបានរៀននូវជំនាញនេះបានរយៈពេលបីឆ្នាំមកម្ល៉េះ ។

ចាន់ណា បញ្ជាក់ថា : "ខ្ញុំចេញគូរគំនូរលក់ពីរឆ្នាំហើយ" ។ សព្វថ្ងៃគំនូររបស់ចាន់ណាអាចលក់នោះ មានតម្លៃចាប់ពី ១៥ដុល្លារ ៣០ដុល្លារ និង៥០ដុល្លារ ។ គំនូរដែលមានតម្លៃ១៥ដុល្លារ គឺមានទំហំក្រដាស A៤ រីឯតម្លៃ ៣០ដុល្លារ គឺមានទំហំ ត្រឹម A៤ x ២ ហើយចំពោះតម្លៃ ៥០ដុល្លារ វិញ នោះ គឺមានទំហំ A៤ x ៣ ។ ចំណែកទីផ្សារលោកមាននៅភ្នំពេញ និងខេត្តសៀមរាប ។

គំនូរដែលចាន់ណាច្រើនគូរ នោះជាប្រភេទគំនូរពណ៌ទឹក ប្រេង និងគំនូរគូរដោយប្រើប្រាស់ខ្មៅដៃ ។ ចាន់ណាបញ្ជាក់ថា រូបភាពដែលលោកអាចលក់ដាច់បានច្រើននោះ គឺជាប្រភេទរូបភាព ដែលនិយាយពីប្រាសាទបុរាណខ្មែរ នៅក្នុងខេត្តសៀមរាប រូបភាពពីទេសភាពនៅស្រុកស្រែចំការ និងរូបភាពដែលមានចរិតវប្បធម៌ប្រពៃណីខ្មែរ ។

សព្វថ្ងៃនេះ សិល្បៈគំនូរគឺជាប្រភេទសិល្បៈមួយដែលកំពុងពេញនិយមនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅពេលដែលឧស្សាហកម្មទេសចរណ៍ កំពុងតែរីកចម្រើនជាមួយនឹងកំណើនភ្ញៀវជារៀងរាល់ឆ្នាំ ។

## អំណាន

### រឿង ទុំទាវ




គឺជារឿងដែលមានប្រជាប្រិយភាពខ្លាំងក្លានៅក្នុងស្រទាប់ប្រជាជនខ្មែរ ទាំងក្មេងទាំងចាស់ដោយសាររឿងនេះ មានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សា និងផលិតជាខ្សែភាពយន្តផងដែរ ។ ប៉ុន្តែទន្ទឹមនឹងនេះចំនួនអ្នក ដែលបានអានស្នាដៃរឿងទុំទាវនៅមានកំណត់នៅឡើយ ដែលនេះជាប្រការគួរឱ្យសោកស្តាយ ។ ក្រៅអំពីសាច់រឿងមានភាពប្រាកដនិយម និងបង្ហាញព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនាសម័យកាលនោះ (សម័យលង្វែកនៅសតវត្សរ៍ទី១៦) រឿងទុំទាវមានលក្ខណៈពិសេសរបស់ខ្លួន ដែលធ្វើឱ្យក្លាយជាស្នាដៃឯក ក្នុងអក្សរសិល្ប៍បុរាណខ្មែរ ។ រឿងទាំងមូលត្រូវសរសេរឡើងជាពាក្យកាព្យយ៉ាងពិរោះ គឺបទពាក្យ៧ ពីដើមរហូតដល់ចប់ ។ អ្នកអាននឹងអត់ទ្រាំកោតសរសើរមិនបាន នូវទេពកោសល្យរបស់អ្នកនិពន្ធក្នុងការបង្កើតនូវអត្ថបទរណ្តំណៃងណងល្អឥតខ្ចោះនោះ ។

រឿងនេះនិពន្ធដោយព្រះបុទមត្ថេរ សោម នៅឆ្នាំ១៩១៥ និងបោះពុម្ពឡើងវិញនៅឆ្នាំ២០០២ ដោយវិជ្ជាស្ថាន ពុទ្ធសាសនបណ្ឌិត្យ ។ សៀវភៅមានកម្រាស់ ១០៥ទំព័រ និងមានតម្លៃ ៥០០០៛ ។

### រឿងព្រះបាទហ៊ុនទៀន




ស្នាដៃនិពន្ធរបស់លោកប៊ីវ ឆៃលាង ដែលថ្មែយកផ្នែកមួយ ក្នុងប្រវត្តិសាស្ត្រខ្មែរ គឺត្រង់វគ្គ ការលើកទ័ពដឹកនាំដោយព្រាហ្មណ៍ម្នាក់ ឈ្មោះកោណ្ឌញ្ញ តាមផ្លូវសមុទ្រមកវាយយកនគរគោកធ្លក (រវាងសតវត្សទី១នៃគ្រិស្តសករាជ) ។ នេះ គឺជាប្រលោមលោកបែបប្រវត្តិសាស្ត្រ ដែលសរសេរឡើងបានយ៉ាងល្អ ដោយបញ្ចេញបញ្ចូលគំនិត ឱ្យចេញជារឿងមួយពេញលេញដោយបង្កើតជាតួអង្គទីកន្លែង ព្រឹត្តិការណ៍ ប្រទាក់ក្រឡាពីវគ្គមួយ ទៅវគ្គមួយទៀត ។

ព្រាហ្មណ៍កោណ្ឌញ្ញ ដែលជារាជបុត្រមួយអង្គ របស់ក្សត្រនៃក្រុងឥន្ទបត្តបុរីរបស់ប្រទេសឥណ្ឌាបានចាកចេញពីមាតុប្រទេសដោយសារតែទំនាស់ក្នុងរាជវង្សានុវង្ស ។ ទ្រង់ធ្វើដំណើរតាមសំពៅមកដល់នគរជ្វា ។ ទ្រង់បញ្ចៀសសង្គ្រាមជាមួយប្រទេសនេះ ហើយរស់នៅយ៉ាងសុខសាន្ត ។ រាត្រីមួយទ្រង់សុបិនឃើញ ទេវតាឱ្យទ្រង់ចាកចេញអំពីនគរជ្វាជាប្រញាប់ជាមួយធ្នូទិព្វ ដើម្បីស្វែងរកអនាគតភរិយា... ។

រឿងនេះគឺត្រូវបានបោះពុម្ពឡើងវិញនៅឆ្នាំ២០០៤ ដែលមានកម្រាស់ ១៣៣ ទំព័រ និងតម្លៃ ៥០០០រៀល ។

**ហួត សុជាតា**





# សិង្ហបុរី : នាគនៅអាស៊ីអាគ្នេយ៍

**អាន ឡូរ៉ំ ប៉ូរ៉ែ**




មកទល់នឹងសម័យអាណានិគម ប្រទេសសិង្ហបុរីរួមនិងកោះតូចៗ ប្រមាណ ៦០ទៀត ដែលផ្សំបានជាប្រជាជាតិដ៏តូចបំផុតនៅអាស៊ីអាគ្នេយ៍នេះ ធ្លាប់ជាផ្នែកមួយរបស់ប្រទេសម៉ាឡេស៊ី ។ ជោគជតារបស់ប្រជាជាតិនេះត្រូវបានធ្វើឱ្យកម្រើកជាមួយនឹងការមកដល់នៃលោកតូម៉ាស ស្តាមហ្វ័ដ រ៉ាហ្វល (Thomas Stamford Raffles) ។ ជនជាតិអង់គ្លេសរូបនេះ បានចុះហត្ថលេខាជាមួយនឹងព្រះចៅស៊ុលតង់ ដែលនឹងអនុញ្ញាតឱ្យកោះនេះក្លាយជាទីតាំងជំនួញមួយ របស់ក្រុមហ៊ុនអង់គ្លេសប្រចាំ នៅតំបន់ឥណ្ឌាបូពា ។ កោះក៏បានក្លាយទៅជាមូលដ្ឋាននាវាចរណ៍ ដែលអនុញ្ញាតឱ្យអាជ្ញាធរអង់គ្លេសតាំងមូលដ្ឋាន បើប្រៀបធៀបទៅនឹងប្រទេសអាណានិគមបារាំង ឬហូឡង់ ដែលមកតំបន់អាស៊ីអាគ្នេយ៍ ។

នៅដំណាច់សតវត្សរ៍ទី១៩ សិង្ហបុរីស្ថិតនៅក្រោមអាណានិគមអង់គ្លេសជាផ្លូវការ ។ កម្មករៗជាច្រើននាក់ ជាជនជាតិចិន និងឥណ្ឌា បានមកតាំងទីលំនៅ និងធ្វើជាគូលីជញ្ជូនទំនិញឡើងចុះកប៉ាល ។ រីឯជនជាតិម៉ាឡេ ដែលជាប្រជាជនរស់នៅលើកោះ ពួកគេច្រើនតែជាអ្នកនេសាទ និងបើកបរកប៉ាល់ ។

នៅសង្គ្រាមលោកលើកទីពីរ កងទ័ពអង់គ្លេស បានបរាជ័យក្នុងសមរភូមិ ទល់នឹងកងទ័ពជប៉ុន ។ ដូច្នេះជប៉ុនគ្រប់គ្រងសិង្ហបុរី ។ រយៈពេលប៉ុន្មានខែពួកគេបានបន្សល់ទុកការចងចាំដ៏ខ្មៅងងឹតបំផុត នៅក្នុងប្រវត្តិសាស្ត្ររបស់សិង្ហបុរី ។

នៅពេលចប់សង្គ្រាម សិង្ហបុរី បានត្រឡប់មកស្ថិតនៅក្រោមការគ្រប់គ្រងអាជ្ញាធរអង់គ្លេសវិញ និងទទួលបានឯករាជ្យនៅ ២០ឆ្នាំក្រោយមកទៀត ។ នាយករដ្ឋមន្ត្រីទី១របស់ ប្រទេសសិង្ហបុរី លោកលី ក្វាន់យ៉េវ (Lee Kuan Yew) ដែលបានគ្រប់គ្រងអំណាចពីឆ្នាំ១៩៥៩ ដល់ឆ្នាំ១៩៩០ គឺត្រូវប្រយុទ្ធប្រឆាំងនឹងបញ្ហាអត់មានការងារធ្វើដើម្បីធ្វើការលើកស្ទួយកម្រិតជីវភាពប្របជាជន និងការតាំងទីលំនៅថ្មីរបស់ពួកគេ ។

លុះមកដល់ទសវត្សរ៍ឆ្នាំ១៩៨០ សិង្ហបុរីបានក្លាយជាគំរូនៃភាពរុងរឿងខាងសេដ្ឋកិច្ច ជាមួយកំណើនជាប់ឯតទគ្គកម្មខាងនាវាចរណ៍ (សិង្ហបុរីមានកំពង់ផែ ជាប់ចំណាត់ថ្នាក់លេខមួយ នៅលើពិភពលោកខាងចំនួនតោនផ្ទុកទំនិញ) ខាងវិស័យហិរញ្ញវត្ថុនិងពាណិជ្ជកម្ម វិស័យទេសចរណ៍ និងចម្រាញ់ប្រេងកាត... ។ ហើយរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ របររកស៊ីខាងកាស៊ីណូក៏បានបើកដំណើរការដែរ ។

បើគេក្រឡេកមើលទៅក្រោយ ទោះបីជាមានវិបត្តិនៅទ្វីបអាស៊ីនានា មានជាអាទិ៍ដូចជា វិបត្តិហិរញ្ញវត្ថុ នាឆ្នាំ១៩៩៧ និងការរាតត្បាតនៃជំងឺផ្លូវដង្ហើមនៅក្នុងឆ្នាំ២០០៣ក៏ដោយ សិង្ហបុរីនៅតែរក្សាបានអត្រាកំណើនដ៏ខ្ពស់ខាងសេដ្ឋកិច្ច និងនៅអាចផ្តល់ជូនឱ្យប្រជាជនខ្លួនប្រមាណ ៤,៦លាននាក់ នូវជីវភាពរស់នៅដ៏សែនខ្ពស់ ។

ពិតណាស់ ! សន្តិភាពនៅក្នុងសង្គមសិង្ហបុរីត្រូវបានធានាតាមរយៈនៃការលូតលាស់សេដ្ឋកិច្ច និងតាមរយៈការអនុវត្តច្បាប់ប្រកបដោយភាពម៉ឺងម៉ាត់ ។ តួយ៉ាង ទោសប្រហារជីវិត ត្រូវបានអនុវត្តលើគ្រប់រូបភាពនៃឧក្រិដ្ឋកម្ម និងការជួញដូរគ្រឿងញៀន ។ បាតុកម្មមិនត្រូវបានអនុញ្ញាត និងកូដកម្ម ត្រូវបានហាមឃាត់ ។ សេរីភាពខាងសារពត៌មានគឺត្រូវបានកំហិត ។ ពេស្យាកម្មក៏ត្រូវបានហាមឃាត់ផងដែរ ។ អ្នកដែលចោលសំរាមពាសវាលពាសកាល អ្នកបត់ជើងតូចនៅតាមដងផ្លូវ ឬខាកស្តោះផ្តេសផ្តាសនឹងទទួលរងនូវការផាកពិន័យយ៉ាងធ្ងន់ធ្ងរ ។ ប្រសិនបើនរណាម្នាក់ហូប ផឹកទឹកគ្មានរបៀប ឬដឹកជញ្ជូនផ្លែធូរេននៅក្នុងរថភ្លើងក្រោមដី និងរថយន្តក្រុង គេនឹងទទួលរងការផាកពិន័យ ៥០០ ដុល្លារ ។

ភាពតឹងតែងរបស់ច្បាប់ និងការអនុវត្តដោយ ភាពម៉ឺងម៉ាត់ប្រហែលជាអាចពន្យល់បានថា ហេតុអ្វីផ្លូវនៅសិង្ហបុរី មានភាពស្អាត គ្រប់ពេល ជារៀងរាល់ថ្ងៃយប់ ហើយថាតើហេតុអ្វី បានជាអំពើពុករលួយនៅក្នុងសង្គមមានកម្រិតទាបបំផុតនោះ ។

### តើសិង្ហបុរីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយយ៉ាងដូចម្តេច?



Photos : DR

**លោកលី ក្វាន់យ៉េវ ដែលជាបិតាឯករាជ្យជាតិសិង្ហបុរី ជាអ្នកទទួលបន្ទុកនៅខណៈលោកជានាយករដ្ឋមន្ត្រីសម្រាប់ការប្រឆាំងនឹងអំពើពុករលួយ។ លោកបានបង្កើតការិយាល័យស៊ើបការណ៍មួយលើការប្រព្រឹត្តអំពើពុករលួយ ដែលនៅក្នុងការិយាល័យនោះ លោកបានផ្តល់អំណាច ដើម្បីឃាត់ខ្លួនអ្នកប្រព្រឹត្តស្វែងរកសាក្សី អង្កេតលើគណនីនៅធនាគាររបស់ជនសង្ស័យម្នាក់ៗ និងគ្រួសាររបស់គេ។ ទោះបីជារដ្ឋមន្ត្រីក៏ដោយ ក៏មិនអាចរួចខ្លួនបានដែរ។**

October-2008.qxd 10/7/2008 10:52 AM Page 16

# ល្បែងកំសាន្ត

**សង្កេត**

*សូមប្អូនជួយនាងតូចនេះ រកកន្ត្រករបស់នាងផង។ នៅក្នុងកន្ត្រករបស់នាងមាន ផ្លែចេក៤ ផ្លែប៉ោម២ ពងមាន់៣ និងសាលាដ ១ដុំ។*




**ចម្លើយ : ទំព័រ៣**

សូមថ្លែងអំណរគុណដល់អង្គការស៊ីប៉ាដែលជួយឧបត្ថម្ភទំព័រនេះ។

អង្គការស៊ីប៉ា : ប្រអប់សំបុត្រ ៣១ ផ្ទះលេខ៩ ផ្លូវ២១ រាជធានីភ្នំពេញ-កម្ពុជា ឬទូរស័ព្ទ : ០២៣ ២១៦ ០០១។

## សេចក្តីជូនដំណឹង !

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក
នឹងមានរៀបចំការប្រឡងប្រជែងខាងគូរគំនូរ
លើប្រធានបទអំពី "សិទ្ធិកុមារ" ។
លក្ខខណ្ឌចូលរួមប្រឡង : កុមារគ្រប់ៗរូប ដែល
មានអាយុពី ៨ឆ្នាំ ទៅដល់១៦ឆ្នាំ ។
សូមប្អូនៗផ្ញើគំនូរមកកាន់អាសយដ្ឋានការិយាល័យយើង
តាមរយៈលោកឪពុក ឬបងស្រីដែលនៅជិតបំផុត
ឱ្យបានមុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ខាងមុខនេះ ។

## ការងារប្រចាំខែ

- នៅដើមខែតុលា : មានការសាងសង់ព្រះវិហារ និងសាលាមត្តេយ្យនៅឃុំត្រែងត្រយឹង ដោយព្រះសហគមន៍ក្រុងព្រះសីហនុ។
- ចាប់ពីខែតុលា : មានពិធីអធិដ្ឋានគាំ នៅព្រះសហគមន៍ក្រុងព្រះសីហនុតាមផ្ទះគ្រីស្តបរិស័ទ។
- ថ្ងៃទី១ តុលា : បើកបវេសនកាលថ្មី មត្តេយ្យសាលាពន្លកថ្មី នៅព្រះសហគមន៍បាត់ដំបង។
- ថ្ងៃទី២ តុលា : មានប្រជុំបូជាចារ្យ និងដូនជីនៅក្នុងភូមិភាគកំពង់ចាម នៅព្រះសហគមន៍ខេត្តព្រៃវែង។
- ថ្ងៃទី៥ តុលា : មត្តេយ្យសាលានៅព្រះសហគមន៍តូតាំងនៅស្រុកស្អាង បើកទទួលសិស្សឱ្យចូលរៀន សម្រាប់បវេសនកាលថ្មី។
- ថ្ងៃទី៦ តុលា : មត្តេយ្យសាលាសន្តិតេរ៉េសា បើកទទួលសិស្សឱ្យចូលរៀន នៅព្រះសហគមន៍ចំណោម ភូមិភាគបាត់ដំបង។
- ថ្ងៃទី១០ តុលា : ពិធីបើកបវេសនកាលសាលាមត្តេយ្យពន្លកថ្មីកែវមុន្នី នៅមណ្ឌលកសិដ្ឋានគ្រាប់ ខេត្តពោធិ៍សាត់។
- ថ្ងៃទី១២ តុលា : បងប្អូនពេញវ័យទទួលការអប់រំជំនឿពេលរសៀល បន្តការជួបជុំគ្នាឡើងវិញនៅព្រះវិហារសន្តយ៉ូសែប។
- ថ្ងៃទី១៨-១៩ តុលា : សិក្ខាសាលាគ្រូអប់រំជំនឿរៀបចំដោយមជ្ឈមណ្ឌលវប្បធម៌កាតូលិក នៅសាលាដុនបូស្កូ ទឹកថ្លា រាជធានីភ្នំពេញ។
- ថ្ងៃទី១៩ តុលា : មានរៀបចំពិធីអភិបូជា និងប្រគល់មុខងារប្រកាសដំណឹងល្អជូនគ្រូអប់រំជំនឿ (ក្នុងទិវាបេសកកម្មពិភពលោក) ប្រារព្ធធ្វើនៅព្រះវិហារកំពង់រទេះ។
- ថ្ងៃទី២៨ តុលា ដល់ថ្ងៃទី៦ វិច្ឆិកា : គណៈប្រតិភូមួយក្រុមមានគ្នាប្រមាណ ២០នាក់ មកពីសហរដ្ឋអាម៉េរិក ចូលរួមជួយសាងសង់មណ្ឌលក្មេងៗ នៅកំពង់ឃ្លាំង ខេត្តសៀមរាប។
- ថ្ងៃទី៣០ ខែតុលា : ខួបប្រាំឆ្នាំនៃវិទ្យាស្ថានសន្តហ្វ្រង់ស្វ័រ នៅឃុំគួស ស្រុកត្រាំកក់ ខេត្តតាកែវ។
- ថ្ងៃទី៣១ តុលា : មានរៀបចំការប្រគុំតន្ត្រីអ៊ីរ៉ុបបែបក្លាស៊ីក (បុរាណ) ប្រារព្ធធ្វើនៅព្រះវិហារសន្តយ៉ូសែប។
- ថ្ងៃទី៤ វិច្ឆិកា : ប្រជុំបូជាចារ្យណែនាំព្រះសហគមន៍ភូមិភាគភ្នំពេញ។
- ថ្ងៃទី២៥ វិច្ឆិកា : សំណាក់ធម៌បូជាចារ្យភូមិភាគភ្នំពេញ។